F06 - 24

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ



# មេរៀនទី៦

## អំពី

# ប្រព័ន្ធត្រួតពិនិត្យ និងវាយតំលៃ
# លើការងារ PIMD និង ស.ក.ប.ទ

រៀបចំដោយៈ ក្រសួងធនធានទឹក និងឧតុនិយម

ភ្នំពេញ, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០៣

# សំ រេ ច

**ប្រការ ១:**

អនុញ្ញាតដាក់អោយប្រើប្រាស់ជាផ្លូវការនូវឯកសារមេរៀនជាមូលដ្ឋានចំនួន ០៧ ដើម្បីអនុវត្តការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផល និងកិច្ចអភិវឌ្ឍន៍ (PIMD) ក្នុងទិសដៅបង្កើត និងអភិវឌ្ឍន៍សហគមន៍កសិករប្រើប្រាស់ទឹក (ស.ក.ប.ទ) ដូចមានក្នុងឧបសម្ព័ន្ធទី១, ២, ៣, ៤, ៥ ,៦ និងទី៧ នៃប្រកាសនេះជាភាសាខ្មែរ និងភាសាអង់គ្លេស។

**ប្រការ ២:**

គ្រប់អង្គភាពចំណុះក្រសួងធនធានទឹក និងឧតុនិយម ត្រូវប្រឹក្សាជាប្រចាំជាមួយក្រសួងធនធានទឹក និងឧតុនិយម (នាយកដ្ឋានធារាសាស្ត្រកសិកម្ម) ដើម្បីប្រើប្រាស់ឯកសារនេះអោយមានប្រសិទ្ធិភាពខ្ពស់ និងចំទិសដៅ។

**ប្រការ ៣:**

គ្រប់អង្គភាពចំណុះក្រសួងធនធានទឹក និងឧតុនិយម ត្រូវសហការប្រកបដោយស្មារតីយកចិត្តទុកដាក់ផ្សព្វផ្សាយដល់គ្រប់ស្រទាប់កសិករប្រើប្រាស់ទឹកដែលមានទីតាំងជាប់ប្រព័ន្ធធារាសាស្ត្រទាំងអស់នៅទូទាំងប្រទេសកម្ពុជា រួចត្រូវរាយការណ៍ពីប្រសិទ្ធិភាព និងលទ្ធផលការងារជូនក្រសួងធនធានទឹក និងឧតុនិយម ជាប្រចាំ។

**ប្រការ ៤:**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥:**

អគ្គនាយក អគ្គាធិការ និងគ្រប់អង្គភាពចំណុះក្រសួងធនធានទឹក និងឧតុនិយម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី 30 ខែ 7 ឆ្នាំ ២០០៣

**រដ្ឋមន្ត្រី**

**លឹម_គានហោ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម
- ដូចក្នុងប្រការ ៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី...6...នៃប្រកាសលេខ...151...ប្រក.ធទឧ

ចុះថ្ងៃទី.....30.......ខែ........03........ឆ្នាំ២០០៣

# មេរៀនទី៦

# អំពី

# ប្រព័ន្ធត្រួតពិនិត្យ និងវាយតំលៃ

# លើការងារ PIMD និង ស.ក.ម.ធ

រៀបចំដោយៈ ក្រសួងធនធានទឹក និងឧតុនិយម

ភ្នំពេញ, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០៣










សិក្ខាសាលាជាតិស្តីពី ស.ក.ប.ទ និង PIMD នៅសណ្ឋាគារ Le Royal ទីក្រុងភ្នំពេញ






ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម
ថ្លែងសន្ទរកថាបើកសិក្ខាសាលា ស្តីពី ស.ក.ប.ទ និង PIMD ដោយសង្កត់ធ្ងន់
លើការអនុវត្តន៍អោយមានប្រសិទ្ធិភាពខ្ពស់លើផែនការសកម្មភាពរយៈពេលវែង
ស្តីពី ស.ក.ប.ទ និង PIMD របស់ក្រសួងធនធានទឹក និងឧតុនិយម



ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ជំរាបជូនសមាជិករាជរដ្ឋាភិបាល អង្គការ NGOs និងស្ថានទូតប្រទេសនានា ប្រចាំប្រទេសកម្ពុជា ADB WB និងក្រសួងពាក់ព័ន្ធ នូវគោលបំណងរបស់គំរោងអភិវឌ្ឍន៍ និងគ្រប់គ្រងវិស័យប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព ក្នុងគំរោងអភិវឌ្ឍន៍ភាគខាងលិចរាជធានីភ្នំពេញ ។




World Bank គាំទ្រ និង សរសើរ នូវលទ្ធផល
ការងាររបស់ក្រសួងធនធានទឹក និងឧតុនិយម
លើការរៀបចំ ស.ក.ប.ទ និងអនុវត្ត PIMD







កិច្ចប្រជុំបច្ចេកទេសដើម្បីផ្លាស់ប្តូរយោបល់ និងពិភាកក្សារកថវិកាដើម្បីគាំទ្រកម្មវិធី PIMD និង ស.ក.ប.ទ របស់ប្រទេសកម្ពុជា

នៅប្រទេសជប៉ុន IWMI-HQ Colombo- Sri Lanka ប្រទេសចិន និង ប្រទេសស៊ុយអ៊ែត



វគ្គបណ្តុះបណ្តាលស្តីពី IMT (Irrigation Management Transfer) នៅខេត្តសៀមរាប
រៀបចំឡើងដោយក្រសួងធនធានទឹក និងឧតុនិយម និងស្ថានទូតសហព័ន្ធអាឡឺមង់ប្រចាំប្រទេសកម្ពុជា


SEILA INFRASTRU
19 _ 22
ការរៀបចំផែនការការងារប្រតិបត្តិ និងរយៈពេលមធ្យម
លើការងារ ស.ក.ប.ទ និង PIMD ក្នុងកម្មវិធី Seila



សិក្ខាសាលា [illegible] PIMD














ការរៀបចំផែនការការងារតាមបែបវិមជ្ឈការក្នុងការជួសជុលប្រព័ន្ធធារាសាស្ត្រទំនប់អូរត្រែង ផែនការការងារសំរាប់រៀបចំ ស.ក.ប.ទ
និងអនុវត្តគោលនយោបាយ PIMD



ប្រព័ន្ធធារាសាស្ត្រទំនប់អូរត្រែងត្រូវបានធ្វើការជួសជុលដោយក្រសួងធនធានទឹក និងឧតុនិយម ក្រោមគំរោងឥណទានកម្មវិធី ADB 1445 CAM SF

ដើម្បីអនុវត្តការរៀបចំ ស.ក.ប.ទ និងគោលនយោបាយ PIMD គំរូជូនទូទាំងប្រទេស



ប្រព័ន្ធធារាសាស្ត្រកប់សេះក្នុងពេលកំពុងជួសជុល
និងក្រោយពេលជួសជុលហើយ ក្នុងគោលបំណងអនុវត្តនូវការរៀបចំ ស.ក.ប.ទ និង PIMD



វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្មី PIMD ជំនាន់ ១.២.៣ នៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម



[illegible]



ការចុះពង្រឹងសមត្ថភាពរបស់ ស.ក.ប.ទ ដែលបានរៀបចំ
រួចហើយលើការងារ ស.ក.ប.ទ និង PIMD

# ម ា តិ កា

**ទំព័រ**


មេរៀនទី៦ ........................................ ១៤៥

១- សារឡើងវិញមេរៀនទី៥ ........................................ ១៤៥

២- ទស្សនៈរួមនៃមេរៀនទី៦ ........................................ ១៤៥

៣- គោលការណ៍ជាមូលដ្ឋានសំរាប់ប្រព័ន្ធត្រួតពិនិត្យ និងវាយតំលៃ ........................................ ១៤៦

  ៣-១- គោលបំណងនៃការត្រួតពិនិត្យ និងវាយតំលៃ ........................................ ១៤៦

  ៣-២- គុណវិបត្តិរួមនៃ M & E ........................................ ១៤៧

  ៣-៣- គោលការណ៍ណែនាំសំរាប់ M & E ........................................ ១៤៧

៤- ជំហាន ៥ យ៉ាងក្នុងការរៀបចំផែនការ និងអនុវត្តប្រព័ន្ធ M & E ........................................ ១៤៨

៥- ជំហានទី ១ : រកតំរូវការពិតមាន ........................................ ១៤៩

  ៥-១- ប្រភេទ ៤ យ៉ាងនៃការវាស់ស្ទង់របស់ M & E ........................................ ១៤៩

  ៥-២- ធ្វើការពិគ្រោះយោបល់ដើម្បីរកសន្ទស្សន៍ ........................................ ១៥០

៦- ជំហានទី ២ : ជ្រើសរើស និងកំណត់សន្ទស្សន៍ ........................................ ១៥៣

  ៦-១- ពតិមានជាមូលដ្ឋាន ........................................ ១៥៣

  ៦-២- សន្ទស្សន៍អំពីទុនជាធនធាន ........................................ ១៥៦

  ៦-៣- សន្ទស្សន៍អំពីការអនុវត្តន៍ ........................................ ១៥៦

  ៦-៤- សន្ទស្សន៍អំពីលទ្ធផល ........................................ ១៦០

  ៦-៥- សន្ទស្សន៍អំពីផលប៉ះពាល់ ........................................ ១៦០

៧- ជំហានទី ៣ : ការប្រមូល និងគ្រប់គ្រងទិន្នន័យ ........................................ ១៦៤

  ៧-១- ផែនការប្រមូលទិន្នន័យ ........................................ ១៦៤

  ៧-២- ផែនការគ្រប់គ្រង និងបញ្ចូលទិន្នន័យ ........................................ ១៦៤

  ៧-៣- ទំរង់បែបបទ Matrix ការទទួលខុសត្រូវ : ផែនការសំរាប់ នរណាធ្វើអ្វី ........................................ ១៦៥

៨- ជំហានទី ៤ : របាយការណ៍ និងការប្រើប្រាស់លទ្ធផល M & E ........................................ ១៦៥

  ៨-១- រៀបចំកិច្ចការប្រជុំពិនិត្យ PIMD ឡើងវិញ និងការបង្ហាញលទ្ធផល ........................................ ១៦៥

  ៨-២- ការប្រើប្រាស់ M & E ដើម្បីគាំទ្រការធ្វើសេចក្ដីសំរេចចិត្ត ........................................ ១៦៦

៩- ឧទាហរណ៍នៃទំរង់បែបបទផែនការសំរាប់ប្រព័ន្ធ M & E ........................................ ១៦៦

១០- ក្រុមលំហាត់ដែលបានស្នើឡើងសំរាប់មេរៀនទី ៦ វគ្គទី ១ ............................................ ១៦៧
១១- សង្ខេបមេរៀន ........................................................................................................ ១៦៧

# មេរៀនទី ៦

## *ប្រព័ន្ធត្រួតពិនិត្យ និងវាយតំលៃសំរាប់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម ពីអ្នកទទួលផល និងកិច្ចអភិវឌ្ឍន៍*

## វគ្គទី ១ : ការបណ្តុះបណ្តាលក្នុងថ្នាក់

### ១. សារឡើងវិញមេរៀនទី ៥

១- អ្នករាយការបង្ហាញការសង្ខេបខ្លីៗអំពីមេរៀនទី ៥ វគ្គទី ១ បន្ទាប់មកមានសំណួរនិងចំម្លើយសំរាប់បំភ្លឺ

២-សិក្ខាកាមបង្ហាញការអនុវត្តន៍ជាក្រុមក្នុងមេរៀនទី ៥ វគ្គទី ២ បន្ទាប់មកមានការពិភាក្សា ។

### ២. ទស្សនៈរួមនៃមេរៀនទី ៦

គោលបំណងនៃមេរៀនទី ៦ គឺដើម្បីបង្កើតការយល់ដឹងរបស់សិក្ខាកាមអំពីប្រពន្ធ័ត្រួតពិនិត្យ និងវាយតំលៃ (M&E) សមស្របមួយដើម្បីគាំទ្រការអនុវត្តន៍ និងកិច្ចអភិវឌ្ឍន៍ច្រើនទៀតលើគោលនយោបាយ ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផល និងកិច្ចអភិវឌ្ឍន៍ (PIMD) នៅកម្ពុជា ។ មេរៀននេះនឹងឱ្យសិក្ខាកាមរៀបចំ និងអនុវត្តប្រពន្ធ័ M&E ។ ប្រពន្ធ័ M&E សំរាប់កម្មវិធី PIMD រួមមានសមាសភាពដូចខាងក្រោមនេះ:

១- គោលបំណងរបស់ប្រពន្ធ័ M&E

២- គោលការរៀបចំ M&E

៣- តម្រូវការពតិមាន PIMD

៤- តម្រូវការពតិមាន ទិន្នន័យនិងសន្ទស្សន៍ដែលត្រូវប្រមូល

៥- វិធីសាស្ត្រដើម្បីប្រមូលទិន្នន័យនិងការគ្រប់គ្រង (ដែលត្រូវកំណត់ក្នុងសិក្ខាកាម និងកំណត់ដោយលេខាធិការដ្ឋានជាតិរបស់ PIMD)

៦- តួនាទីរបស់អ្នកពាក់ពន្ធ័ផ្សេងៗក្នុងដំណើរការ M&E

៧- ការរៀបចំដើម្បីប្រើប្រាស់លទ្ធផល

៨- កម្មវិធីសំរាប់ការអនុវត្ត

៩- តម្រូវការធនធានសំរាប់ការអនុវត្តន៍ដោយជោគជ័យ ។

***<u>ប្រពន្ធ័M&E ត្រូវឈរលើទស្សនៈដែលM&E ត្រូវមាន :</u>***

១- ភាពងាយស្រួល

២- ភាពច្បាស់លាស់

៣- ផែនការទ្រទ្រង់ និងតម្រូវការធ្វើសេចក្តីសំរេចចិត្ត

៤- ភាពពាក់ពន្ធ័ និងប្រយោជន៍របស់អ្នកពាក់ពន្ធ័ទាំងអស់

៥- ភាពរួមបញ្ចូលយ៉ាងត្រឹមត្រូវក្នុងកម្មវិធីអនុវត្ត។

## ៣. គោលការណ៍ជាមូលដ្ឋានសំរាប់ប្រពន្ធ័ត្រួតពិនិត្យ និងវាយតំលៃ

### *៣.១. គោលបំណងនៃការត្រួតពិនិត្យ និងវាយតំលៃ*

ការត្រួតពិនិត្យនិងវាយតំលៃ (M&E) នឹងត្រូវបានរៀបចំហើយត្រូវអនុវត្តទូទាំងប្រទេសដោយចាប់ផ្តើមពីខេត្តសាកល្បងដំបូងដែលផ្តល់ហិរញ្ញប្បទានដោយកម្មវិធីប្រាក់កម្ចីរបស់ ADB ហើយដែលអាចរួមបញ្ចូលប្រពន្ធ័ធារាសាស្ត្រទាំងអស់នៅក្នុងប្រទេស។ ប្រពន្ធ័ M&E នឹងផ្តល់មូលដ្ឋានទិន្នន័យអំពីទិដ្ឋភាពរូបវន្តជាមូលដ្ឋាននៃសំណង់ប្រព័ន្ធធារាសាស្ត្រ និងបរិស្ថាន លក្ខខណ្ឌ័នៃហេដ្ឋារចនាសម្ពន្ធ័សំណង់ប្រព័ន្ធធារាសាស្ត្រ ដំណើរការនិងលទ្ធផលនៃការរៀបចំ ស.ក.ប.ទ និងក្រុមទ្រទ្រង់ ស.ក.ប.ទ ដំណើរការនិងលទ្ធផលនៃការកែលំអរហេដ្ឋារចនាសម្ពន្ធ័ដោយមានការចូលរួម ដំណើរការនិងលទ្ធផលនៃការផ្សព្វផ្សាយកសិកម្ម និងការអនុវត្តន៍ធារាសាស្ត្រកសិកម្ម។

គោលបំណងនៃប្រពន្ធ័ M&E គឺដើម្បីផ្តល់មូលដ្ឋានទិន្នន័យនៃពត៌មានចាំបាច់ទាំងអស់ដើម្បីឱ្យរាជរដ្ឋាភិបាលកម្ពុជាអាចៈ

១- រៀបផែនការ និងត្រួតពិនិត្យការអនុវត្តន៍ PIMD

2- កែតម្រូវ និងអភិវឌ្ឍន៍ថែមទៀតលើយុទ្ធសាស្ត្រ និងគោលនយោបាយ PIMD

៣- ប្រមូលធនធានបន្ថែមទៀតសំរាប់ធារាសាស្ត្រកសិកម្មទ្រទ្រង់ PIMD

គោលបំណងច្បាស់លាស់របស់ប្រពន្ធ័ M&E គឺដើម្បីទទួលទិន្នន័យពាក់ពន្ធ័ បង្កើតមូលដ្ឋានទិន្នន័យសមស្របមួយ និងចេញផ្សាយរបាយការណ៍អំពី PIMD ទាន់ពេលវេលា។ ប្រពន្ធ័នេះនិងរួមមានពត៌មាន និងសមាសភាពដូចខាងក្រោមៈ

១- លក្ខខណ្ឌ័នៃសំណង់ប្រព័ន្ធធារាសាស្ត្រមុនពេលអន្តរាគមន៍

២- ការវិវត្តន៍ និងបញ្ហានានាដែលបានជួបប្រទះក្នុងការអនុវត្តន៍ការកសាងសមត្ថភាព PIMD និងការផ្តល់ សេវាកម្មគាំទ្រ

៣- ការវិវត្តន៍ និងបញ្ហានានាដែលបានជួបប្រទះក្នុងការបង្កើត និងការកសាងសមត្ថភាព ស.ក.ប.ទ

៤- ការវិវត្តន៍ និងបញ្ហានានាដែលបានជួបប្រទះក្នុងការកែលំអរហេដ្ឋារចនាសម្ពន្ធ័ដោយមានការចូលរួម

៥- ទិន្នផលអំពីការអភិវឌ្ឍន៍ ស.ក.ប.ទ ការកែលំអរហេដ្ឋារចនាសម្ពន្ធ័ និងការផ្តល់សេវាកម្មគាំទ្រ

៦- ផលប៉ះពាល់អំពីការអភិវឌ្ឍន៍ ស.ក.ប.ទ ការកែលំអរហេដ្ឋារចនាសម្ពន្ធ័ និងការផ្តល់សេវាកម្មគាំទ្រ

## ៣.២. គុណវិបត្តិរួមនៃ M&E

ការតាមដាននិងវាយតំលៃជាផ្នែកដ៏ទៀងទាត់មួយនៃកម្មវិធីអភិវឌ្ឍន៍ ប៉ុន្តែជារឿយៗវាត្រូវបានរៀបចំ អនុវត្ត និងប្រើប្រាស់មិនបានល្អ។ គុណវិបត្តិរួមនៃ M&E គឺ :

១- វាបង្កើតពត៌មានមិនត្រឹមត្រូវ និងច្រើនហួសពេក។ ជារឿយៗអ្នកបច្ចេកទេសឬទីប្រឹក្សាបានរៀបចំប្រពន្ធ័ M&E ស្មុគស្មាញ និងលំអិតពេកដោយមិនបានគិតពីរបៀបត្រូវប្រមូល និងប្រើប្រាស់ពត៌មាន។

2- អ្នកធ្វើសេចក្តីសំរេចចិត្តមិនប្រើប្រាស់លទ្ធផល។ វាអាចកើតឡើងដោយសារទិន្នន័យច្រើនហួសពេក ដោយសារ មិនបានរៀបចំប្រពន្ធ័ឱ្យខ្លីឱ្យច្បាស់លាស់ និងឱ្យងាយស្រួលដោយសារគេមិនបានគិតឱ្យ ប្រពន្ធ័នេះមានភាពត្រឹមត្រូវ ឬដោយសារមិនមានឱ្យអ្នកត្រូវការវាប្រើប្រាស់ទាន់ពេល។ ក៏អាចកើតឡើងផងដែរដោយសារវេទិការសំរាប់ ពិនិត្យគំហើញរបស់ M&E និងការធ្វើសេចក្តីសំរេចចិត្តមិនត្រូវ បានបង្កើតឡើងឬមិនដំណើរការ។

៣- ទិន្នន័យដែលបានប្រមូល មិនមែនជាពត៌មានដែលអ្នកពាក់ពន្ធ័ទាំងអស់ត្រូវការ។ វាកើតឡើងដោយសារអ្នក ធ្វើផែនការមួយក្រុមតូចមិនបញ្ចូលកំរិតសន្ទស្សន៍ទាំងអស់សំរាប់ PIMD។ ជារឿយៗ M&E ផ្តោតលើសហគមន៍កសិករប្រើប្រាស់ទឹក និងការអនុវត្តន៍ធារាសាស្ត្រកសិកម្ម ប៉ុន្តែបំភ្លេចចោលនូវទិដ្ឋភាពពាក់ពន្ធ័នានា ដូចជាសមត្ថភាព និងធារាសាស្ត្រសកម្មភាពរបសីភ្នាក់ងារការអភិវឌ្ឍន៍កសិកម្ម ការដោះស្រាយទីផ្សារ និងទំនាក់ទំនងជាមួយរដ្ឋបាលមូលដ្ឋាន។

៤- ទំរង់គំរូមិនអាចឱ្យយកជាការបាន។ វាកើតឡើងដោយសារទិន្នន័យមិនត្រូវបានប្រមូលពីក្បាល ភាគកណ្តាល និងកន្ទុយប្រឡាយជ្រើសរើសកសិករដោយព្រាវៗគំរូមានទំហំតូចពេក។

៥- ទំរង់គំរូមិនអាចឱ្យប្រៀបធៀបជាផ្លូវការបាន " មុនពេលឬក្រោយពេលអន្តរាគមន៍ " ឬ " ដោយមាន ឬដោយ គ្មានអន្តរាគមន៍ "វាកើតឡើងដោយសារមិនមានមូលដ្ឋានទិន្នន័យឬដោយសារមិនប្រមូលទិន្នន័យមុនពេល អន្តរាគមន៍ឬដោយសារប្រពន្ធ័ឯទៀតដែលមិនមានអន្តរាគមន៍ត្រូវបានជ្រើសរើសសំរាប់ M&E

## ៣.៣. គោលការណ៍ណែនាំសំរាប់ M&E

គេអាចជៀសវាងគុណវិបត្តិទាំងនេះបានដោយការអនុម័តគោលការណ៍ណែនាំដូចខាងក្រោម:

១- រក្សាពត៌មានដែលត្រូវការឱ្យមានភាពងាយស្រួល និងច្បាស់លាស់ការរៀបប្រពន្ធ័ M&Eមួយគួរចាប់ផ្តើម ពីការវាយតំលៃ[illegible]តម្រូវការរបស់អ្នកធ្វើសេចក្តីសំរេចចិត្តនិងអ្នកពាក់ពន្ធ័ និងការវិភាគអំពីសមត្ថភាពដែលមាន កំរិតរបស់ពួកគេដើម្បីប្រមូលពត៌មាន។ អាចមានកង្វះខាតថវិកា ជំនាញ និងមនុស្សក្នុងការប្រមូលគ្រប់គ្រង និងវិភាគទិន្នន័យ។ គួរប្រមូលតែពត៌មានណាដែលត្រូវការចាំបាច់ប៉ុណ្ណោះ ហើយគួរជៀសវាងកុំប្រមូលពត៌មាន ណាដែលមិនគួរទុកចិត្តឬពត៌មានមិនចាំបាច់ច្រើនហួសពេក។ ពត៌មានដែលបានប្រមូលគួរឱ្យស្របតាមគោលបំណង ហើយងាយបកស្រាយ។ បន្ទាប់ពីមូលនិធិសំរាប់គំរោង

ពិសេស នេះបានបញ្ចប់រួចហើយ រដ្ឋាភិបាលគួរមានប្រពន្ធ័ មានតំលៃថោក និងងាយយល់មួយដែលអាចបន្តទៀតបាន។

២-វិធីធ្វើផែនការឱ្យងាយយល់ និងទាន់ពេលដើម្បីបំពេញនិងនាំមកនូវលទ្ធផល ចំពោះអ្នកពាក់ពន្ធ័ដែលរវល់ក្នុង សិក្ខាសាលា និងកិច្ចប្រជុំរៀបផែនការ។ គេមិនសូវអានរបាយការណ៍វែងពេកទេ។ ការបង្ហាញ និងរបាយការណ៍ គួរផ្តោតតែលើគំហើញឬលទ្ធផលសំខាន់ៗ ដោយប្រើទំរង់ដែលខ្លី ច្បាស់លាស់ហើយបង្ហាញ តែចំនុចសំខាន់ៗ។ គួររៀបផែនការពីការប្រមូលនិងការវិភាគទិន្នន័យដើម្បីបង្កើតគំហើញនៅពេលអ្នកធ្វើ សេចក្តីសំរេចចិត្តត្រូវការ

៣- ឱ្យអ្នកពាក់ពន្ធ័សំខាន់ចូលរួមក្នុងការរៀបផែនការ និងអនុវត្តកម្មវិធី M&E ហើយត្រូវប្រាកដថាសន្ទស្សន៍ ដែលបានជ្រើសនឹងបង្ហាញពត៌មានដែលអ្នកពាក់ពន្ធ័ត្រូវការនិងចង់បាន។ ហើយត្រូវប្រាកដថាអ្នកពាក់ពន្ធ័សំខាន់ៗ ទាំងអស់នឹងចូលរួមក្នុងវេទិការនាពេលអនាគតដើម្បីពិនិត្យលទ្ធផលឡើងវិញ។ ប្រសិនបើអ្នកពាក់ពន្ធ័សំខាន់ៗចូលរួមបានន័យថាពួកគេនឹងគោរព ហើយត្រូវតែឆ្លើយតបយ៉ាងហ្មត់ចត់ចំពោះលទ្ធផល។

៤- រៀបចំការប្រមូលទិន្នន័យដើម្បីអាចប្រើប្រាស់ និងប្រៀបធៀបបានប្រសិនបើមានតែកន្លែងសាកល្បងមួយចំនួន តូចសំរាប់ M&E ទេនោះបន្ទាប់មកត្រូវបញ្ចូលវាទាំងអស់។ គួរប្រមូលទិន្នន័យមូលដ្ឋានមុនពេលអន្តរាគមន៍ ដើម្បីអាចប្រៀបធៀបស្ថានភាពមុនពេលនិងក្រោយពេលការអនុវត្តន៍ PIMD។ សំណង់ប្រហាក់ប្រហែលគ្នាដែលនៅក្បែរកន្លែងសាកល្បងនោះអាចត្រូវបានធ្វើការត្រួតពិនិត្យបានដើម្បីប្រៀបធៀបលទ្ធផលដោយមាន និង ដោយគ្មាន PIMD ។

៥- រួមបញ្ចូលការវាយតំលៃជនបទដោយមានការចូលរួមនិងការសម្ភាសន៍អ្នកផ្តល់ពត៌មានសំខាន់ៗ ដើម្បីទទួលពត៌មានដែលមានគុណភាពគ្រប់គ្រាន់សំរាប់ឱ្យសន្ទស្សន៍ប្រាប់បរិមាណមានសុពលភាព ហើយផ្តល់ពត៌មានច្បាស់លាស់ អំពីដំណើរការអនុវតន្ត៍ សេចក្តីសង្ឃឹមរបស់អ្នកពាក់ពន្ធ័និងបទពិសោធន៍មិនស្មុគ្រស្មាញ អំពីរបៀបអនុវត្ត PIMD។ អ្នករៀបផែនការគួរពិចារណាអំពីកំរិតសន្ទស្សន៍ដែលវាស់ស្ទង់វត្ថុណាដែលវាត្រូវវាស់ស្ទង់។ ឧទាហរណ៍ សន្ទស្សន៍ប្រាប់ពីអត្រាប្រមូលថ្លៃឈ្នួលដែលកសិករបង់ចំណាយលើប្រព័ន្ធធារាសាស្ត្រ តើទឹកមិនត្រូវបានផ្តល់ទៅ ឱ្យកសិករជាច្រើនឬដូចម្តេច? តើរចនាសម្ពន្ធ័ជាច្រើនដែលមិនដំណើរការសន្ទស្សន៍បង្ហាញថាមានការថែទាំអន់ ឬមានការរៀបចំខុស និងសាងសង់ខុស? ត្រូវការពត៌មានគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបសំណួរទាំងនេះ។

## ៤. ជំហាន ៥ យ៉ាងក្នុងការរៀបផែនការ និងអនុវត្តប្រពន្ធ័ M&E

លេខាធិការដ្ឋានជាតិរបស់ PIMD នឹងទទួលខុសត្រូវក្នុងការសំរបសំរួលផែនការ និងអនុវត្តប្រពន្ធ័ M&E សំរាប់ កម្មវិធី PIMD ប្រពន្ធ័ M&E គួររៀបចំនិងអនុវត្តតាមជំហាន ៥ យ៉ាងខាងក្រោម :

ជំហានទី ១ : រកគំរូវការពត៌មាន

ជំហានទី ២ : ជ្រើសរើសនិងកំណត់សន្ទស្សន៍

ជំហានទី ៣ : ប្រមូលនិងគ្រប់គ្រងទិន្នន័យ

ជំហានទី ៤ : រាយការណ៍ និងប្រើប្រាស់លទ្ធផល M&E

## ៥. ជំហានទី ១ : រកតំរូវការពត៌មាន

### *៥.១. ប្រភេទ ៤ យ៉ាងនៃការវាស់ស្ទង់របស់ M&E*

មានការវាស់ស្ទង់របស់ M&E ចំនួន ៤ ប្រភេទដូចខាងក្រោម :

១- តាមដានការចែកចាយទុន-វាឆ្លើយតបនិងសំណួរថាតើធនធានអ្វីដែលកំពុងត្រូវបានវិនិយោគដើម្បី អនុវត្ត PIMD? និងការចាត់តាំងបុគ្គលិកការិយាល័យ សម្ភាសន៍ និងធនធានឯទៀតដើម្បីអនុវត្ត PIMD ។

២- តាមដានការអនុវត្តន៍-វាឆ្លើយតប និងសំណួរខាងក្រោម :

- តើ PIMD កំពុងត្រូវបានអនុវត្តតាមផែនការឬទេ? (គោលដៅពេលវេលាកំណត់និតិវិធី)
- តើមានបញ្ហាអ្វីកំពុងកើតឡើងក្នុងពេលអនុវត្ត?
- តើមេរៀនអ្វីដែលយើងបានសិក្សាពីការអនុវត្តន៍?
- តើគួរកែតំរូវយុទ្ធសាស្ត្រអនុវត្តរបៀបណា ?

តាមដានការអនុវត្តន៍ត្រូវការពត៌មានអំពីសកម្មភាពសំខាន់ៗទាំងអស់ដែលត្រូវធ្វើក្នុងអំឡុងពេលដំណើរ ការបង្កើតក្រុមទ្រទ្រង់ ស.ក.ប.ទ ការអភិវឌ្ឍន៍ ស.ក.ប.ទ ការកែលំអរហេដ្ឋារចនាសម្ពន្ធ័និងការផ្តល់សេវាកម្ម គាំទ្រ ។

៣- ការត្រួតពិនិត្យលទ្ធផល-វាឆ្លើយតប និងសំណួរខាងក្រោម :

- តើ ស.ក.ប.ទ និងក្រុមទ្រទ្រង់ ស.ក.ប.ទ ត្រូវមានសមត្ថភាពកំរិតណា?
- តើអ្វីជាប្រសិទ្ធិភាពដោយផ្ទាល់ និងជាបន្ទាន់នៃការអនុវត្តន៍ PIMD លើការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងធារាសាស្ត្រកសិកម្ម?

តាមដានលទ្ធផលត្រូវការពត៌មានអំពីលទ្ធផលដោយផ្ទាល់ និងជាបន្ទាន់ពីការអនុវត្តន៍ ដូចជាសកម្មភាព និងវិនិយោគដោយ ស.ក.ប.ទ ការអនុវត្តន៍របស់ ស.ក.ប.ទ ក្នុងការផ្តល់ទឹក ថែទាំនិងកែលំអរហេដ្ឋារចនាសម្ព័ន្ធ អត្រាប្រមូលថ្លៃឈ្នួល និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ ស.ក.ប.ទ ការពេញចិត្តរបស់សមាជិក ស.ក.ប.ទ និង ផលិតភាពកសិកម្ម ។ ការត្រួតពិនិត្យលទ្ធផលផ្តល់ពត៌មានសំខាន់ៗដើម្បីឱ្យអ្នករៀបផែនការកែតំរូវយុទ្ធសាស្ត្រ អនុវត្ត PIMD ។

៤- វាយតំលៃផលប៉ះពាល់-ការវាយតំលៃមានបំណងក្នុងការប៉ាន់ប្រមាណផលប៉ះពាល់ឬប្រសិទ្ធិភាពជាចុង ក្រោយនៃយុទ្ធសាស្ត្រ PIMD លើគោលបំណងអភិវឌ្ឍន៍សំខាន់ៗ ។ ជាធម្មតាគេត្រូវការពេលវេលា ៣ ឬ

៤ឆ្នាំក្រោយ ពេលអនុវត្តដើម្បីវាស់ស្ទង់ការផ្លាស់ប្តូរក្នុងសន្ទស្សន៍អភិវឌ្ឍជាមូលដ្ឋាន។ ការវាយតំលៃឆ្លើយតប និងសំណួរ ខាងក្រោម :

- តើចង់ឱ្យផលប៉ះពាល់របស់ PIMDកើតឡើងក៏រិតណាចំពោះការអភិវឌ្ឍន៍ និងប្រជាជននៅជនបទ
- តើជា PIMD ឬដែលបណ្តាលឱ្យមានផលប៉ះពាល់ឬចំនុចឯទៀត ?
- តើយុទ្ធសាស្រ្តជាមូលដ្ឋាន និងគោលនយោបាយ PIMD ត្រូវការកែតំរូវឬធ្វើឱ្យទាន់សម័យឬទេ

បន្ទាប់ពីរយៈពេល ៣ ឬ ៤ ឆ្នាំ មេរៀនត្រូវបានសិក្សា ឯលក្ខខណ្ឌបានផ្លាស់ប្តូរ។ វាអាចមានការចំបាច់ត្រូវកែតំរូវគោលនយោបាយ PIMD។ ការកែតំរូវនេះត្រូវការ ការវិភាគមួយអំពីប្រសិទ្ធិភាពឬផលប៉ះពាល់ របស់ PIMD។ ជាធម្មតាការវាយតំលៃមួយធ្វើការប្រៀបធៀបសំណង់ដែល PIMD ត្រូវបានអនុវត្ត និងសំណង់ដែលមិនបានអនុវត្ត PIMD។ ឬអាចប្រៀបធៀបសន្ទស្សន៍អនុវត្តក្នុងសំណង់មុនពេល និងក្រោយពេលអនុវត្ត PIMD។ ជាធម្មតាគេត្រូវការរយៈពេលយ៉ាងតិច ៣ ឆ្នាំ (៥ឆ្នាំជាការប្រសើរ) ក្រោយពេលអនុវត្ត PIMD ក្នុងតំបន់មួយមុន និងក្រោយវាយតំលៃផលប៉ះពាល់។

ឧទាហរណ៍នៃប្រសិទ្ធិភាពឬផលប៉ះពាល់របស់ PIMD លើការអភិវឌ្ឍរួមមាន:

១- ការដោះស្រាយការងារក្នុងវិស័យកសិកម្ម

២- ប្រាក់ចំណូលរបស់គ្រួសារកសិករ

៣- សុខភាពរបស់ប្រជាជននៅជនបទ

៤- និរន្តរភាពនៃធារាសាស្រ្តកសិកម្ម

៥- អភិរក្សធនធានធម្មជាតិ

៦- ការនាំចេញផលកសិកម្ម

## ៥.២. ធ្វើការពិគ្រោះយោបល់ដើម្បីរកសន្ទស្សន៍

សន្ទស្សន៍របស់ M&E គួរឆ្លុះបញ្ចាំងគោលបំណង និងប្រយោជន៍របស់អ្នកពាក់ពន្ធ័ផ្សេងៗរួមមានកសិករ មន្រ្តីរដ្ឋបាលស្រុក និងខេត្តដែលពាក់ពន្ធ័ធារាសាស្រ្តកសិកម្ម NGOs អ្នករៀបផែនការថ្នាក់ជាតិ និងអ្នកធ្វើគោលនយោបាយ។ លេខាធិការដ្ឋានរបស់ PIMD គួរធ្វើការពិគ្រោះយោបល់ ៣ យ៉ាងដើម្បីទទួលពត៌មានអំពីគោលបំណង និងប្រយោជន៍របស់អ្នកពាក់ពន្ធ័សំខាន់ៗអំពី PIMD។ ការពិគ្រោះយោបល់មានប្រយោជន៍ក្នុងការជ្រើសរើសសន្ទស្សន៍។ តារាងទី ១ ខាងក្រោមបង្ហាញទំរង់បែបបទដែលអាចប្រើសំ រាប់រៀបផែនការប្រពន្ធ័ M&E។

## *សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ*

លេខាធិការដ្ឋានជាតិរបស់ PIMD គួរប្រារព្ធសិក្ខាសាលាពិភាក្សាថ្នាក់ជាតិមួយជាមួយបុគ្គលិកមកពីក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងពាក់ព័ន្ធ ពីថ្នាក់ជាតិ និងខេត្ត (ពីខេត្តសាកល្បងទាំង11) ពី NGOs និងអ្នក ជំនាញបច្ចេកទេសដើម្បីរកវង្វាស់អនុវត្តជាគន្លឹះនិងសន្ទស្សន៍ដែលត្រូវបញ្ចូលក្នុង M&E សំរាប់ PIMD ។ ក្រុមតូចៗអាចរកសន្ទស្សន៍សំរាប់ប្រភេទនិមួយៗនៃសន្ទស្សន៍ទាំង ៤ប្រភេទ (ទុន ដំណើរការអនុវត្ត លទ្ធផល និងផលប៉ះពាល់) ។សន្ទស្សន៍គួរបញ្ចូលនូវទុនមនុស្ស និងហិរញ្ញវត្ថុ សកម្មភាពរៀបចំ និងបណ្តុះបណ្តាលការរៀបចំសាងសង់ការជួសជុល និងកែលំអរទិដ្ឋភាពជារូបវន្ត បរិស្ថាន និងបច្ចេកទេស O&M ទិដ្ឋភាពរៀបចំផលិតភាពសេដ្ឋកិច្ច ធារាសាស្ត្រកសិកម្ម និងលក្ខខណ្ឌសង្គម-សេដ្ឋកិច្ច។ អ្នកចូលរួមត្រូវប្រុងប្រយត្ន័ដោយមិនជ្រើសរើសសន្ទស្សន៍ច្រើនពេកទេដែលអាចបណ្តាលឱ្យប្រពន្ធ័ M&E មានភាព ពិបាកនិងស្មុគ្រស្មាញ ។

សិក្ខាសាលានេះនឹងត្រូវការរយៈពេល ២ ថ្ងៃដែលចែកជាសម័យប្រជុំចំនួន៥ ដូចខាងក្រោម:

១- សម័យប្រជុំទី ១ : ការណែនាំឱ្យស្គាល់ PIMD និង M&E (មួយម៉ោងកន្លះ)

២- សម័យប្រជុំទី ២ : ពត៌មានដែលត្រូវការសំរាប់ PIMD (ពីរម៉ោង)

៣- សម័យប្រជុំទី ៣ : ការពិភាក្សាតាមក្រុមដើម្បីរកសន្ទស្សន៍ (ចែកជា ៤ ក្រុមសំរាប់ PIMD : ទុន កិច្ចការអនុវត្ត លទ្ធផលនិងផលប៉ះពាល់ ) (បីម៉ោង)

៤- សម័យប្រជុំទី ៤ : សម័យប្រជុំរួមដើម្បីកំណត់អទិភាពឬកែតំរូវសន្ទស្សន៍និងស្នើសេចក្តីសំរេច (ពីរម៉ោង )

៥- សម័យប្រជុំទី ៥ : ការរៀបចំសំរាប់ការប្រមូលទិន្នន័យ ការគ្រប់គ្រងទិន្នន័យ និងការចែករំលែកទិន្នន័យរវាងនាយកដ្ឋាននានា (មួយម៉ោងកន្លះ )

អ្នកជំនាញខាងគ្រប់គ្រងទិន្នន័យម្នាក់គួរចូលរួមក្នុងសិក្ខាសាលានេះដើម្បីធ្វើជាគ្រូបង្គោល ។

## *ការពិគ្រោះយោបល់ជាមួយកសិករប្រើប្រាស់ទឹក*

ប្រភេទប្រជុំទី ២: ដើម្បីកំណត់តំរូវការពត៌មានសំរាប់ប្រពន្ធ័ M&E គឺការពិគ្រោះយោបល់ក្នុងកិច្ចប្រជុំជាមួយកសិករប្រើប្រាស់ទឹកពី ២០-៣០ នាក់ដែលបានជ្រើសរើសពីប្រពន្ធ័ធារាសាស្ត្រយ៉ាងតិច ៣ ក្នុងខេត្តផ្សេងៗ ។ សំណង់គួរមានតួយ៉ាងពីសំណង់ឯទៀតក្នុងខេត្តហើយមានភាពប្រហាក់ប្រហែល (ឬរួមមាន) សំណង់សាកល្បងសំរាប់ខេត្តនោះ ។

នៅក្នុងការពិគ្រោះយោបល់នេះ គួរឱ្យកសិករនិយាយដោយសេរីអំពីកង្វល់របស់ពួកគេចំពោះ PIMD ការគ្រប់គ្រងទឹក ការអភិវឌ្ឍន៍កសិកម្ម និងបញ្ហាសេដ្ឋកិច្ច-សង្គម ។ គួរសួរកសិករឱ្យផ្តល់មតិនិងសំណើអំពីការកែលំអរដែលពួក គេចង់បានសំរាប់កសិកម្មធារាសាស្ត្ររបស់ពួកគេ ។ បុគ្គលិកលេខាធិការដ្ឋានជាតិដែលដឹកនាំកិច្ចប្រជុំនេះគួរពន្យល់ អំពីសន្ទស្សន៍ជាគន្លឹះខ្លះអំពីការអនុវត្តន៍ PIMD លទ្ធផលនិងផលប៉ះពាល់ហើយស្នើឱ្យកសិករ

បញ្ចេញ្ចេតិលើចំនុច ២ យ៉ាង: ១)- សំណើរបស់ពួកគេអំពីថាតើពួកគេអាចចូលរួមក្នុងការប្រមូលទិន្នន័យដូចម្តេច, ២)- សំណើរបស់ពួក គេអំពីពតិមានដ៏ទៃណាទៀតដែលគួរតាម ដាន ។

ខាងក្រោមនេះគឺជារបៀបវារៈដែលស្នើឡើងសំរាប់ការពិគ្រោះយោបល់របស់កសិករប្រើប្រាស់ទឹក:

1- ការពិភាក្សាដោយចំហរអំពីកសិកម្មធារាសាស្ត្រ-បញ្ហានិងឱកាស (មន្ត្រីរំលឹកកសិករឱ្យចែករំលែកសេចក្តីសង្ឃឹម របស់ខ្លួន )

2- ការពន្យល់អំពី PIMD (ភាគច្រើនមន្ត្រីត្រូវនិយាយ ចំណែកឯកសិករត្រូវបញ្ចេញមតិ)

3- ការពិភាក្សាអំពីកសិករត្រូវធ្វើអ្វីដើម្បីកែលំអរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងកសិកម្ម (មន្ត្រីរំលឹកកសិករ ឱ្យពិភាក្សាគ្នាឱ្យច្រើន)

4- ការពន្យល់អំពីសន្ទស្សន៍ជាយថាហេតុរបស់ M&E (មន្ត្រីពន្យល់ ចំណែកឯកសិករបញ្ចេញមតិ)

5- កសិករបញ្ចេញមតិថាតើពួកគេអាចចូលរួមដូចម្តេចក្នុងការប្រមូលទិន្នន័យឬកត់ត្រាទិន្នន័យសំរាប់ M&E

6- កសិករស្នើពតិមានដ៏ទៃណាទៀតដែលគួរតាមដាន ។

បុគ្គលិកលេខាធិការដ្ឋានជាតិគួរកត់ត្រាយ៉ាងប្រុងប្រយ័ត្ននូវមតិ និងសំណើរបស់កសិករហើយរៀបចំរបាយការណ៍ ខ្លីមួយអំពីទុនដែលបានទទួលពីការពិគ្រោះយោបល់នេះ ។ ពង្រាងរបាយការណ៍គួររៀបលំដាប់តាមរបៀបវារៈនៃប្រធានបទពិភាក្សា ។ គួរកំណត់ចំនួនបុគ្គលិករដ្ឋាភិបាលតែមួយចំនួនតូចឱ្យចូលរួមក្នុងកិច្ចប្រជុំនេះ ហើយពួកគេទាំង នោះមិនគួរនិយាយច្រើនទេ ដើម្បីកសិករអាចសំដែងទស្សនៈផ្ទាល់របស់ខ្លួន ។

## ***<u>ការពិគ្រោះយោបល់ជាមួយមន្ត្រីមូលដ្ឋាន</u>***

ការពិគ្រោះយោបល់ប្រភេទទី ៣: គឺកិច្ចប្រជុំរវាងមន្ត្រីរដ្ឋបាលមូលដ្ឋាន និងបុគ្គលិក NGOs ដែលកំពុងធ្វើការងារ លើធារាសាស្ត្រកសិកម្មក្នុងខេត្ត ។ មន្ត្រីទាំងនេះគួររួមមានមន្ត្រីរដ្ឋបាលស្រុក និងខេត្ត ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងពាក់ពន្ធ័ បុគ្គលិកពាក់ពន្ធ័បច្ចេកទេសនិងបុគ្គលិក NGOs ដែលអាចធ្វើការងារធារាសាស្ត្រកសិកម្មក្នុងខេត្ត ។

ខាងក្រោមនេះគឺជារបៀបវារៈដែលបានស្នើឡើងសំរាប់កិច្ចប្រជុំពិគ្រោះយោបល់របស់មន្ត្រីមូលដ្ឋាន និង NGOs:

១- ការពិភាក្សាដោយចំហរអំពីធារាសាស្ត្រកសិកម្ម-បញ្ហានិងឱកាស

២- ការពន្យល់អំពី PIMD

៣- ការពិភាក្សាអំពីកសិករត្រូវធ្វើអ្វីដើម្បីកែលំអរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

៤- ការពន្យល់អំពី M&E ហេតុអ្វីបានជាវាមានសារៈសំខាន់ និងសន្ទស្សន៍របស់ M&E

៥- អ្នកចូលរួមពិភាក្សាអំពីជំរើសអំពីរបៀបកត់ត្រា ប្រមូលទិន្នន័យ និងបញ្ចូលទិន្នន័យក្នុងកំព្យូទ័រ និងតើនរណាត្រូវធ្វើអ្វី

៦- អ្នកចូលរួមស្នើអំពីពត៌មានដ៏ទៃណាទៀតដែលគួរបញ្ចូលក្នុងប្រពន្ធ័ M&E ។

បុគ្គលិកលេខាធិការដ្ឋានជាតិគួរកត់ត្រាយ៉ាងប្រុងប្រយ័ត្ននូវមតិ និងសំណើរបស់មន្ត្រីមូលដ្ឋាននិងបុគ្គលិក NGO ហើររៀបចំរបាយខ្លីមួយអំពីទុនដែលបានទទួលពីការពិគ្រោះយោបល់នេះ។ ពង្រាងរបាយណ៍ការ គួររៀបលំដាប់តាមរបៀបវារៈនៃប្រធានបទពិភាក្សា។ ទុនដែលបានទទួលពីការពិគ្រោះយោបល់ជាមួយ កសិករ មន្ត្រីមូលដ្ឋាន និងបុគ្គលិក NGOs គួរប្រើប្រាស់ដោយលេខាធិការដ្ឋានជាតិរបស់ PIMD ដើម្បីកែតំរូវសន្ទស្សន៍ចុងក្រោយ ហើយសំរេចការណែនាំសំរាប់ការប្រមូលទិន្នន័យ បញ្ចូលក្នុងកំព្យូទ័រ និងប្រើ ប្រាស់។

តារាងទី២ ខាងក្រោមបង្ហាញឧទាហរណ៏មួយអំពីទំរង់បែបបទដែលអាចប្រើសំរាប់សង្ខេបទុនពីការពិគ្រោះយោបល់នានាស្របតាមក្របខណ្ឌការងារដែលយើងកំពុងប្រើប្រាស់សំរាប់រៀបចំ M&E នៅក្នុងសមាសភាព ៤ យ៉ាង ហើយសំរាប់សមាសភាពនិមួយៗជំរុញពីកង្វល់ឬបញ្ហាសំខាន់ៗឱ្យទៅជាសន្ទស្សន៏ដែលបានស្នើឡើង។

## ៦. ជំហានទី ២ : ជ្រើសរើសនិងកំណត់សន្ទស្សន៏

ក្រោយពេលកិច្ចប្រជុំពិគ្រោះយោបល់បានប្រារព្ធរួចហើយអនុគណៈកម្មាធិការ M&E របស់លេខាធិការដ្ឋានជាតិ នឹងមានបញ្ជីពត៌មានដែលត្រូវការ និងបញ្ជីសន្ទស្សន៏ជាផ្នែកៗ។

### *៦.១. ពត៌មានជាមូលដ្ឋាន*

ជាសំខាន់ត្រូវប្រមូលពត៌មានជាមូលដ្ឋានសំរាប់ប្រពន្ធ័ធារាសាស្ត្រមុនពេលអនុវត្ត PIMD ដើម្បីឱ្យយើងមានពត៌មានអំពីស្ថានភាពមុនពេល PIMD។ ការវាស់ស្ទង់របស់សន្ទស្សន៏ដូចគ្នាក្រោយពេលអនុវត្ត PIMD ផ្តល់នូវមូលដ្ឋាននៃការយល់ដឹងថាតើ PIMD បានជោគជ័យឬអត់ ហើយហេតុអ្វីបានជាដូច្នោះដើម្បីសំរបសំរួលការជ្រើសរើសសន្ទស្សន៏សមស្រប សំរាប់ទិន្នន័យជាមូលដ្ឋាន ខាងក្រោមនេះគឺជាការរាយពត៌មានជាយថាហេតុរបស់ M&E សំរាប់ការពិចារណារបស់សិក្ខាកាមក្នុងមេរៀនទី ៦ (និងអ្នកឯទៀតដែលពាក់ពន្ធ័ក្នុងការសំរេច PIMD ប្រពន្ធ័ M&E)។ ជាថ្មីម្តងទៀត ជាសំខាន់មិនត្រូវជ្រើសរើសសន្ទស្សន៏ច្រើនពេកទេ។ លេខាធិការដ្ឋានជាតិមិនគួរមានអារម្មណ៏បង្ខិតបង្ខំក្នុងការជ្រើសរើសពត៌មានដែលមានខាងក្រោមនេះទេ ។

***<u>ទិន្នន័យជាយថាហេតុអំពីសំណង់ប្រព័ន្ធធារាសាស្ត្រ</u>***

១- ឈ្មោះ និងទីតាំងរបស់សំណង់

២- ប្រភពទឹក និងបច្ចេកវិជ្ជាក្នុងការយកទឹក

៣- ប្រភេទរចនាសម្ពន្ធ័ក្បាលសំណង់

៤- ការផ្គត់ផ្គង់ទឹកជាមធ្យមប្រចាំខែឬរដូវ

៥- សមត្ថភាពប្រឡាយក្នុងការផ្តល់ទឹក

៦- ឆ្នាំដែលសំណង់ត្រូវបានសាងសង់ឡើង ?

៧- ឆ្នាំដែលសំណង់ត្រូវបានទទួលការស្តារជាចុងក្រោយ ?

៨- ប្រភពមូលនិធិសំខាន់សំរាប់ការស្តារជាចុងក្រោយ ?

៩- សមត្ថភាពវាស់ស្ទង់ទឹក

១០- ប្រភេទ និងកំរិតនៃភាពបត់បែនរបស់រចនាសម្ពន្ធ័សំរាប់ត្រួតពិនិត្យទឹក

១១- ប្រភេទ ចំនួននិងលក្ខខណ្ឌដំណើរការរបស់រចនាសម្ពន្ធ័ត្រួតពិនិត្យ

១២- អត្រាភាគរយនៃប្រឡាយសរុប(តាមប្រភេទ)ដែលមិនដំណើរការ និងត្រូវការជួសជុល (ដែលបានកត់សំគាល់ក្នុងអំឡុងពេលរដូវស្រោចស្រព)

១៣- អត្រាភាគរយនៃប្រវែងប្រឡាយសរុប (តាមប្រភេទ) សំរាប់រំហូរដែលមានកំរិតដោយសារវាត្រូវការសំអាត (ដែលបានកត់សំគាល់ក្នុងអំឡុងពេលរដូវស្រោចស្រព )

១៤- តំបន់ស្រោចស្រពក្នុងរដូវប្រាំង និងវស្សាសំរាប់ពេលបច្ចុប្បន្ន និងពីរឆ្នាំមុន ( ហិតា)

១៥- ប្រពលភាពនៃការស្រោចស្រព (%នៃតំបន់ដែលអាចស្រោចស្រពបានដែលបានស្រោចស្រពសំរាប់រដូវវស្សានិងរដូវប្រាំង ) សំរាប់ពេលបច្ចុប្បន្ន និងពីរឆ្នាំមុន ។

## *<u>ទិន្នន័យជាយថាហេតុអំពីការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ</u>*

១- តើការងារចំបងរបស់សំណង់គឺសំរាប់ស្រោចស្រព បង្ហូរឬសំរាប់ត្រួតពិនិត្យទឹកជំនន់ ?

២- ប្រភេទ និងកំរិតសេវាកម្មប្រព័ន្ធធារាសាស្ត្រ និងបង្ហូរដែលបានផ្តល់

៣- ការរៀបចំដែលមានស្រាប់សំរាប់ការចែកចាយ និងផ្តល់ទឹក

៤- តើសហគមន៍កសិករប្រើប្រាស់ទឹកមានស្រាប់នៅក្នុងកំរិតសំណង់ឬទេ ?

៥- តើសមាគមអ្នកប្រើប្រាស់ទឹកមានមេដឹកនាំ បទបញ្ញត្តិ ការរៀបចំសំរាប់ប្រមូលមូលនិធិឬពលកម្មសំរាប់ O&M ឬទេ ?

៦- តើមេដឹកនាំ ក.ក.ប.ទ ត្រូវបានតែងតាំងតាមការបោះឆ្នោតដោយប្រជាធិបតេយ្យឬទេ ?

៧- អត្រាភាគរយនៃកសិករប្រើប្រាស់ទឹកទាំងអស់ដែលជាសមាជិកសហគមន៍

៨- តើ ស.ក.ប.ទ ត្រូវបានបង្កើតឡើងស្របច្បាប់តាមរយៈរដ្ឋបាលខេត្តឬទេ ?

៩- ប្រសិនបើ ស.ក.ប.ទ ប្រមូលថ្លៃឈ្នួលសេវាកម្មប្រព័ន្ធធារាសាស្ត្រ តើគេកំណត់ថ្លៃប៉ុន្មាន ហើយតើអត្រានៃការប្រមូលនោះប៉ុន្មាន ? (ចំនួន / ហិតា % នៃអ្នកប្រើប្រាស់ទឹកដែលបង់ចំ ណាយ)

១០- តើសកម្មភាពដូចខាងក្រោមនេះមួយណា (ចំនួនប៉ុន្មាន) ដែល ស.ក.ប.ទ ដើរតួនាទី គ្រប់គ្រង ? (ការផ្តល់ទឹក ការថែទាំហេដ្ឋារចនាសម្ពន្ធ័ ការប្រមូលថ្លៃឈ្នួល ការពង្រឹងបទបញ្ញត្តិ ការផ្តល់ទុនជាក្រុម ឥណទានជាក្រុម ការដោះស្រាយទីផ្សារជាក្រុម ការកែច្នៃពូជជាក្រុម ការអភិវឌ្ឍន៍កសិ-ពាណិជ្ជកម្មជាក្រុម)

១១- កំរិតនៃការពេញចិត្តរបស់កសិករដែលមានទំនុកចិត្តលើការប្រគល់ទឹក

១២- កំរិតនៃការពេញចិត្តរបស់កសិករលើភាពយុត្តិធមិ (សមភាព) នៃការចែកចាយទឹក

១៣- កំរិតនៃការពេញចិត្តរបស់កសិករលើការឆ្លើយតប (ភាពបត់បែនបាន) នៃការផ្តល់ទឹក

១៤- ការអនុវត្តន៏គ្រប់គ្រងទឹកលើកសិដ្ឋាន (ខាងលើ កណ្តាលនិងការហូរដល់ខាងក្រោម)

## ***ទិន្នន័យជាយថាហេតុអំពីកសិកម្ម***

១- ដំណាំសំខាន់ដែលត្រូវស្រោចស្រព និងដំណាំសំខាន់ទីពីរដែលត្រូវស្រោចស្រព

២- រដូវដាំដុះសំខាន់ (ប្រាំងឬវស្សា)

៣- ទិន្នផលដំណាំជាមធ្យមនាពេលបច្ចុប្បន្ន និងពីរឆ្នាំមុនសំរាប់ដំណាំសំខាន់ និងដំណាំទីពីរ

៤- ប្រពលភាពនៃដំណាំក្នុងសំណង់

៥- អត្រាភាគរយនៃផលស្រូវដែលបានលក់

៦- តើកសិករដាំដំណាំដែលមិនមែនជាស្រូវឬទេ ? ប្រសិនបើមែនប្រាប់ % នៃផលដំណាំដែលបានលក់

៧- តំលៃពីកសិដ្ឋាននៅទីផ្សារសំរាប់ស្រូវនាពេលបច្ចុប្បន្ន និងពីរឆ្នាំមុន

៨- តំលៃពីកសិដ្ឋាននៅទីផ្សារសំរាប់ដំណាំទីពីរនាពេលបច្ចុប្បន្ន និងពីរឆ្នាំមុន

៩- អត្រាភាគរយនៃតំបន់ស្រោចស្រពក្នុងរដូវប្រាំងលើដំណាំមិនមែនជាស្រូវ

១០- ចំនួនកសិករជាអ្នកស្រោចស្រពដែលស្ទូងសំណាប (ទល់និងពូជដែលបានផ្សាយ )

១១- អត្រា %នៃកសិករដែលប្រើប្រាស់ជីរ

## ***ទិន្នន័យជាយថាហេតុអំពីសេដ្ឋកិច្ច-សង្គម***

១- ចំនួនកសិករជាអ្នកស្រោចស្រពក្នុងសំណង់ដែលជាម្ចាស់ដី ទល់និងចំនួនអ្នកជួលដីពីគេ

២- ចំនួនម្ចាស់ដីដែលបានសិទ្ធិកាន់កាប់ដី

៣- ថ្លៃឈ្នួលជាមធ្យមប្រចាំថ្ងៃសំរាប់ពលកម្មកសិកម្មនាពេលបច្ចុប្បន្ន និងពីរឆ្នាំមុន

៤- ចំនួនកសិករជាអ្នកស្រោចស្រពក្នុងសំណង់ដែលគ្រួសារទទួលប្រាក់ចំណូលច្រើនជាង 50% ក្រៅពីធារាសាស្ត្រកសិកម្ម

៥- ចំនួនមនុស្ស ចំនួនថ្ងៃ របស់ពលកម្មដែលបានជួលហើយប្រើប្រាស់លើកសិដ្ឋាន របស់កសិករជាអ្នកស្រោចស្រពក្នុងសំណង់

៦- តួនាទីរបស់ស្ត្រីក្នុងការស្រោចស្រព ការបង្វែរបស់កសិកម្មក្នុងទំរង់គ្រួសារកសិករ

៧- ចំនួនមនុស្ស ចំនួនថ្ងៃដែលចំណាយដោយគ្រួសារកសិករជាអ្នកស្រោចស្រពលើការថែទាំប្រពន្ធ័ធារាសាស្ត្រក្នុងរដូវដាំដុះលើកមុន។

សន្ទស្សន៍ជាមូលដ្ឋានដែលបានជ្រើសរើសគួរប្រមូលមុនពេលអន្តរាគមន៍ PIMD ហើយបន្ទាប់មកសំរាប់រយៈពេលមួយឆ្នាំៗរហូតដល់យ៉ាងតិចរយៈពេល ៥ ឆ្នាំក្រោយពេលដែល ស.ក.ប.ទ ត្រូវបានបង្កើត និងទទួលការគ្រប់គ្រង សំណង់ក្នុងសំណង់សាកល្បងរបស់ PIMD ។

## ៦.២. *សន្ទស្សន៍អំពីទុនជាធនធាន*

ខាងក្រោមនេះគឺជាសន្ទស្សន៍សំរាប់តាមដានការចំណាយធនធានដ៏ទៃទៀតដែលបានប្រើប្រាស់សំរាប់អនុវត្ត PIMD ។

១- ចំណាយសំរាប់កម្មវិធី PIMD តាមសកម្មភាពនិមួយៗនៅថ្នាក់ជាតិជាខែ

២- ចំណាយសំរាប់កម្មវិធី PIMD តាមសកម្មភាពនិមួយៗនៅថ្នាក់ខេត្ត និងនៅថ្នាក់សំណង់សាកល្បងជាខែ

៣- ចំនួនបុគ្គលិកដែលត្រូវបានតែងតាំងទៅអនុវត្តកម្មវិធី PIMD តាមមុខងារ កំរិត និងអង្គការ គួសង្ខេបពតិមានផ្នែកហិរញ្ញវត្ថុក្នុងសេចក្តីថ្លែងការណ៍តាមខែនៃការចំណាយ ប៉ុន្តែគួររាយការណ៍មួយត្រីមាសម្តងទៅឱ្យលេខាធិការដ្ឋានជាតិ ។

## ៦.៣. *សន្ទស្សន៍អំពីការអនុវត្តន៍*

ខាងក្រោមនេះគឺជាជំហាន ១២ យ៉ាងដែលបានស្នើឡើងក្នុងដំណើរការរៀបចំ ស.ក.ប.ទ ការកសាងសមត្ថភាព ស.ក.ប.ទ និងការផ្ទេរការទទួលខុសត្រូវលើការគ្រប់គ្រងធារាសាស្ត្រទៅឱ្យ ស.ក.ប.ទ ។ ចំនួននៃជំហានទាំងឡាយ និងសកម្មភាពសំខាន់ៗត្រូវបានរាយនៅផ្នែកខាងឆ្វេង ។សន្ទស្សន៍ជាយថាហេតុសំរាប់ជំហាននិមួយៗត្រូវបានរាយនៅផ្នែកខាងស្តាំ (ជាអក្សរទ្រេត) ។ ការរាយទាំងអស់នេះច្រើនបន្តិច ក្នុងបំណងដើម្បីផ្តល់គំនិតយ៉ាងបរិបូរណ៍ សំរាប់ការពិចារណា ។ គួរពិភាក្សា និងកែតំរូវចំនុចទាំងអស់នេះ តាមត្រូវការ ។ លេខាធិការដ្ឋានជាតិគួរចងចាំថា:

### ជំហានអនុវត្ត និងសន្ទស្សន៍ :កំរិតសំណង់

| **ជំហានក្នុងការអនុវត្តន៍ <u>នៅកំរិតសំណង់</u>** | **<u>សន្ទស្សន៍</u> ជាយថាហេតុ** |
|---|---|
| <u>ជំហានទី ១</u> | *- មេរៀនណែនាំឱ្យស្គាល់* |
| (កិច្ចប្រជុំរៀបចំ ) | *- មេរៀន PRA អំពីបញ្ហា និងឱកាស* |
| | *- មេរៀនរៀបផែនការជំហានបន្ទាប់* |
| <u>ជំហានទី ២</u> | *- រកព្រំប្រទល់នៃអង្គភាពរៀបចំទឹកនៅកំរិតនិមួយៗ* |
| (កំណត់រូបសណ្ឋានទឹកនៃអង្គការ អ្នកប្រើប្រាស់ទឹក ) | *- រកឈ្មោះនៃសមាជិករបស់អង្គភាពនិមួយៗ* |

ជំហានទី ៣

ផែនការ

(ការបង្កើតបទបញ្ញាត្តិ

ដែលត្រូវការគណៈកម្មាធិការព្រាង

លក្ខន្តិកៈ ស.ក.ប.ទ )

- *មេរៀនដើម្បីពិភាក្សាជំនួយ PIM រកការជួសជុល& កែលំអរ& ការព្វកិច្ចរបស់កសិករក្នុងដំណើរការ PIM*

- *បោះឆ្នោតជ្រើសតាំងគណៈកម្មធិការព្រាងលក្ខន្តិកៈ* ស.ក.ប.ទ

ជំហានទី ៤

(ការជ្រើសរើស&បណ្តុះបណ្តាល

អ្នករៀបចំកសិករ )

*មេរៀនដើម្បីពិភាក្សាតួនាទី& ចរិតលក្ខណៈរបសអ្នករៀបចំកសិករ(FO's)*

- *FO's ជ្រើសរើសដោយគណៈកម្មាធិការព្រាង*

- *ការបណ្តុះបណ្តាលបឋមដល់ FO's& ការរៀបចំផែនការការងាររបស់ពួកគេ*

ជំហានទី ៥

(ការរៀបចំនិងអនុម័ត

លក្ខន្តិកៈ ស.ក.ប.ទ )

- *ការណែនាំរបស់គណៈកម្មាធិការព្រាង*

- *គណៈកម្មាធិការនាយកបំពេញពង្រាងលក្ខន្តិកៈ*

- *ពង្រាងលក្ខន្តិកៈត្រូវបានពិភាក្សា& កែតំរូវក្នុងកិច្ចប្រជុំទូទៅរបស់អនាគតសមាជិក*

ជំហានទី ៦

(ការបង្កើត ក.ក.ប.ទ &

ស.ក.ប.ទ )

- *ការបោះឆ្នោតជ្រើសតាំងអ្នកតំណាង ក.ក.ប.ទ*

- *ការបោះឆ្នោតជ្រើសតាំងអ្នកតំណាងគណៈកម្មាធិការប្រឡាយទីពីរនិងទីបី( បើត្រូវការ)*

- *ការបោះឆ្នោតជ្រើសតាំងអ្នកតំណាងគណៈកម្មាធិការនាយករបស់ ស.ក.ប.ទ*

- *តើការបោះឆ្នោតមានការប្រកួរប្រជែងគ្នានិងតើបានប្រើសន្លឹកឆ្នោតសម្ងាត់ឬទេ ?*

*-% នៃសមាជិក ស.ក.ប.ទ ដែលបានចូលរួមក្នុងការបោះ ឆ្នោត*

ជំហានទី ៧

( ការចុះបញ្ជីផ្លូវច្បាប់របស់ ស.ក.ប.ទ

រួមមានការទទួលស្គាល់លក្ខន្តិកៈ

&គណៈកម្មាធិការនាយក ស.ក.ប.ទ )

- *ស.ក.ប.ទ ចុះបញ្ជីជាមួយក្រសួងធនធានទឹក និងឧតុនិយម*

- *រដ្ឋាភិបាលទទួលស្គាល់លក្ខន្តិកៈនិងគណៈកម្មាធិការនាយកដ្ឋាន* ស.ក.ប.ទ

| | |
|---|---|
| ជំហានទី ៨<br>(ការជួសជុល&កែលំអរហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ) | *- ការសិក្សាជាមុន*<br>*- រៀបចំពង្រាង ពិភាក្សា កែតំរូវ និងយល់ព្រមដោយ ស.ក.ប.ទ និងក្រសួងធនធានទឹក និងឧតុនិយម (តាមរយៈក្រុមទ្រទ្រង់)*<br>*- ស.ក.ប.ទ រៀបផែនការ& អនុវត្តការរួមវិភាគទានរបស់ខ្លួន*<br>*- ក្រសួងធនធានទឹក និងឧតុនិយម អនុវត្តតួនាទីរបស់ខ្លួនក្នុងការសាងសង់ (ផ្ដាក& ការពឹងផ្អែកអាស្រ័យលើការរួមវិភាគទានរបស់កសិករ)*<br>*- ត្រូវសាកល្បងហេដ្ឋារចនាសម្ព័ន្ធដែលបានជួសជុល& និងគណៈកម្មាធិការនាយក* ស.ក.ប.ទ *ចុះហត្ថលេខាព្រមព្រៀង*<br>*- តំលៃការកែលំអរក្នុងមួយហិតា*<br>*- ការចែករំលែកតម្លៃសរុបដោយ* ស.ក.ប.ទ |
| ជំហានទី ៩<br>(ការរៀបចំរូមលើផែនការ O&M & ថវិកា) | *- តែងតាំងបុគ្គលិកគ្រប់គ្រងធារាសាស្ត្រ*<br>*- បណ្តុះបណ្តាលបុគ្គលិក& មន្ត្រី ស.ក.ប.ទ អំពីការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ*<br>*- រៀបចំផែនការ O&M & ថវិកាដោយគណៈកម្មា នាយក* ស.ក.ប.ទ *& ក្រុមទ្រទ្រង់ PIM*<br>*- ការគណនាថ្លៃឈ្នួលសេវាកម្មធារាសាស្ត្រ* |
| ជំហានទី ១០<br>(ការព្រមព្រៀងលើផែនការ O&M ថវិកា& ថ្លៃឈ្នួល) | *- ពិភាក្សា& ព្រមព្រៀងលើផែនការ O&M ថវិកា& និងថ្លៃឈ្នួលក្នុងកិច្ចប្រជុំធំរបស់* ស.ក.ប.ទ<br>*FWUC បើកគណនីធនាគារ*<br>*- ការប្រមូលថ្លៃឈ្នួលសេវាកម្មធារាសាស្ត្រ*<br>*- ការអនុវត្តន៏ផែនការ O&M តាមរដូវ* |
| ជំហានទី ១១<br>(កិច្ចព្រមព្រៀងផ្ទេរ) | *- គណៈកម្មាធិការនាយក* ស.ក.ប.ទ *មន្ត្រីឯទៀត& ក្រុមទ្រទ្រង់ PIM ពិភាក្សាអំពីគំរូកិច្ចព្រមព្រៀងផ្ទេរ*<br>*- ពង្រាងកិច្ចព្រមព្រៀងផ្ទេរត្រូវបានរៀបចំពិភាក្សាកែតំរូវ និងយល់ព្រមដោយ* ស.ក.ប.ទ *& ក្រុមទ្រទ្រង់ PIM* |

- *កិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខាដោយគណៈកម្មាធិការនាយក ស.ក.ប.ទ និងក្រសួងធនធានទឹក និងឧតុនិយម*

| | |
|---|---|
| <u>ជំហានទី ១២</u><br>(ការបន្តការកសាងសមត្ថភាព& ការផ្តល់សេវាកម្មគាំទ្រ ) | - *ការបណ្តុះបណ្តាលម្តងម្កាលដល់* ស.ក.ប.ទ<br>- *សវនកម្មប្រចាំឆ្នាំលើការគ្រប់គ្រងធារាសាស្ត្រ*<br>- *កិច្ចព្រមព្រៀងសេវាកម្ម (ដែលគ្រប់គ្រងរួមគ្នាឬដោយភាគីទីបី)*<br>- *រដ្ឋាភិបាលផ្អាកការឧបត្ថម្ភធនសំរាប់ថវិកា O&M*<br>- *ការបង្កើតនិងដំណើរការនៃមូលនិធិជួសជុលធារាសាស្ត្រនិងការកែលំអរ*<br>- *ការវាយតម្លៃអំពីគោលគំនិតកសិករនិងសំណើអំពីដំណើរការ PIM មេដឹកនាំ* ស.ក.ប.ទ *ផែនការ O&M & ថ្លៃឈ្នួលនិងដីទៃទៀត* |

## ***<u>ជំហានអនុវត្ត និងសន្ទស្សន៍ : ថ្នាក់ជាតិ</u>***

អ្វីដែលបានរៀបរាប់ខាងលើគឺជាជំហាននិងសន្ទស្សន៍សំរាប់ការត្រួតពិនិត្យ ការអនុវត្តន៍នៅកំរិតសំណង់ឬកំរិតខេត្តខាងក្រោមនេះគឺជាការរាយគោលបំណង និងសន្ទស្សន៍សំរាប់ការអនុវត្តន៍ PIMD នៅថ្នាក់ជាតិ ។

| **<u>គោលបំណងនៃ</u>**<br>**ការអនុវត្តថ្នាក់ជាតិ** | - **<u>សន្ទស្សន៍</u>**<br>- **ដែលអាចជ្រើស** |
|---|---|
| ១- ការបង្កើររចនាសម្ពន្ធ័កម្មវិធី | - *ការបង្កើតលេខាធិការដ្ឋានសំរាប់ PIMD*<br>- *ការបណ្តុះបណ្តាលបុគ្គលិកលេខាធិការដ្ឋាន*<br>- *វេទិកាជាតិសំរាប់ PIM*<br>- *សិក្ខាសាលាណែនាំឱ្យស្គាល់ PIM (ថ្នាក់ជាតិ& ថ្នាក់ ខេត្ត)* |
| ២- ការរៀបចំទិសដៅជាថ្មី& ការកសាងសមត្ថភាពបុគ្គលិកក្រសួងធនធានទឹក និងឧតុនិយម | - *បង្កើតក្រុមទ្រទ្រង់ PIM ថ្នាក់ខេត្ត*<br>- *ការបណ្តុះបណ្តាលក្រុមទ្រទ្រង់ PIM*<br>- *ចំនួនបុគ្គលិកថ្នាក់ស្រុក& ខេត្តដែលត្រូវតែងតាំងទៅ PIM & ដំណើរការគាំទ្រ ស.ក.ប.ទ* |

- % នៃបុគ្គលិកដែលត្រូវតែងតាំងទៅ PIM & ការផ្តល់សេវកម្មគាទ្រដែលត្រូវការចំណេះដឹងនិងជំនាញ (វាស់ស្ទង់ដោយការធ្វើតេស្ត)
- អនុវត្តសវនកម្មលើការគ្រប់គ្រងធារាសាស្ត្រ
- ការបង្កើតមូលនិធិកែលំអរធារាសាស្ត្រថ្នាក់ខេត្ត

៣- ការបង្កើតប្រពន្ធ័ M&E សំរាប់ PIM

- សិក្ខាសាលាដើម្បីសំរេចយកសន្ទស្សន៏វិធីសាស្ត្រប្រមូលទិន្នន័យ បញ្ចូលក្នុងកំព្យូទ័រ និងការប្រើប្រាស់
- កិច្ចការ M&E ធ្វើដោយ ស.ក.ប.ទ
- ការអនុវត្តន៏កិច្ចការ M&E ដោយបុគ្គលិកថ្នាក់ស្រុក និងក្រុមទ្រទ្រង់ PIM ថ្នាក់ខេត្ត
- ក្រុមទ្រទ្រង់ PIM ថ្នាក់ខេត្តនិងលេខាធិការដ្ឋានពិនិត្យទិន្នន័យ M&E ឡើងវិញក្នុងកិច្ចប្រជុំធ្វើផែនការ

## ៦.៤.សន្ទស្សន៏អំពីលទ្ធផល

| **គោលបំណង** | **- សន្ទស្សន៏** |
|---|---|
| **លទ្ធផលគោលនយោបាយ** | **ជាយថាហេតុ** |
| " ការពង្រីងតំបន់ស្រោចស្រព " (គោលនយោបាយ១.១) | - ហិតា បានស្រោចស្រព រដូវវស្សា<br>- ហិតា បានស្រោចស្រព រដូវប្រាំង<br>- សុរបតំបន់បានស្រោចស្រពប្រចាំឆ្នាំ |
| ការអនុវត្តន៏ប្រតិបត្តិការ& ភាពរឹងមាំនៃការគ្រប់គ្រងរបស់កសិករ គោលនយោបាយ ១.៤&២.៣ | - ចំនួនជម្លោះលើវិស័យទឹក/ ឆ្នាំ<br>- ផលនៃការស្រោចស្រព<br>- ការផ្តល់ទឹកតាមចំណែក (បរិមាណដែលបានផ្តល់/ គោលដៅ)<br>- ចំណែកនៃតំបន់ដែលបានស្រោចស្រពទៅដល់តំបន់បានស្រោចស្រពបាន<br>- % នៃតំបន់អាចស្រោចស្រពដោយមានប្រឡាយដែលជីកដោយកសិករ<br>- គំរូគោលគំនិតរបស់កសិករអំពីទំនុកចិត្ត ភាពគ្រប់គ្រាន់ និងយុត្តិធម៌ក្នុងការផ្តល់ទឹក |

| | |
|---|---|
| | - ធ្វើតេស្តពីចំណេះដឹងនិងជំនាញរបស់មន្ត្រី ស.ក.ប.ទ ក្នុងការទទួលនិងផ្តល់ទឹក<br>- % នៃកិច្ចការប្រតិបត្តិសំខាន់ៗអនុវត្តដោយសកបទ (តាមផែនការសេវាកម្មធារាសាស្ត្រនិមួយៗ) |
| "ការថែទាំដោយនិរន្តរភាពដោយកសិករ"<br>(គោលនយោបាយ ១.៤&២.៣) | - ការចំណាយលើការថែទាំ ហិតា/ ឆ្នាំ<br>- ការចំណាយលើការថែទាំ ហិតា/ ឆ្នាំជា% នៃតំលៃបង្ហើយការថែទាំដែលនៅសេសសល់<br>- បរិមាណដីល្បាប់ដែលបានស្តារបានពីប្រឡាយ<br>- % នៃរចនាសម្ព័ន្ធសរុបដែលដំណើរការ<br>- % នៃប្រវែងប្រឡាយដែលត្រូវបានជួសជុលនិងសំអាត (ក្នុងអំឡុងពេលស្រោចស្រព)<br>- ការធ្វើតេស្តលើចំណេះដឹង& ជំនាញរបស់មន្ត្រី ស.ក.ប.ទ ក្នុងការថែទាំ& ជួសជុលម្តងម្កាល<br>- % នៃកិច្ចការថែទាំសំខាន់ៗដែលអនុវត្តដោយ ស.ក.ប.ទ (តាមផែនការសេវាកម្មធារាសាស្ត្រនិមួយៗ) |
| " កសិករចង់បង់ចំណាយសំរាប់ O&M " | - អត្រាប្រមូលថ្លៃឈ្នួល (% នៃចំនួនគោលដៅដែលបានប្រមូល)<br>- ចំនួនធនធានដែលរកបានដោយ ក.ក.ប.ទ ជា% នៃតំលៃសរុបរបស់ O&M<br>- ចំណែកនៃគិតថ្លៃឈ្នួលជាគោលដៅចំពោះតំលៃសរុបរបស់ O&M |
| និរន្តរភាពហិរញ្ញវត្ថុនៃប្រពន្ធ័ធារាសាស្ត្រ<br>(គោលនយោបាយ 2.4) | - តម្លៃធារាសាស្ត្រជា% នៃតម្លៃរួមនៃផលិតផលក្នុងសំណង់<br>- % នៃការចំណាយធារាសាស្ត្រលើសំណង់ដែលចំណាយដោយអ្នកប្រើប្រាស់ទឹក<br>- ការចំណាយសរុបលើO&M ជា% នៃតម្លៃសរុបO&M<br>- ចំណែកនៃចំនួនក្នុងមូលនិធិទុនបំរុងរបស់សកបទ |

| | |
|---|---|
| | *៨% នៃថវិកាប្រចាំឆ្នាំរបស់ O&M*<br>- *ការបំពេញគណនីហិរញ្ញវត្ថុដោយសកបទសំរាប់ សមាសភាគសំខាន់និមួយៗ*<br>- *ការវាយតំលៃពីសវនកម្មលើការគ្រប់គ្រងធារាសាស្ត្រ* |
| តួនាទីរបស់រដ្ឋាភិបាលដែលត្រូវបន្ថយក្នុងធារាសាស្ត្រ O&M (គោលនយោបាយ ១.៤&២.៥) | - *ការចំណាយរបស់រដ្ឋាភិបាលលើធារាសាស្ត្រ O&M ក្នុងមួយហិតា*<br>- *ការចំណាយរបស់រដ្ឋាភិបាលដែលបានចាត់តាំងទៅប្រព័ន្ធធារាសាស្ត្រ O&M* |
| វិនិយោគដែលបង្កើនក្នុងវិស័យធារាសាស្ត្រដោយម្ចាស់ជំនួយនិងទីភ្នាក់ងារជំនួយបច្ចេកទេស (គោលនយោបាយ ១.៤&២.៤) | - *ចំនួនប្រចាំឆ្នាំនៃចំនួនប្រាក់កម្ចីនិងជំនួយឥតចំណងដែលបានចំណាយ*<br>- *ការចំណាយដោយ NGOs លើការអភិវឌ្ឍន៍ធារាសាស្ត្រ*<br>- *ការវិនិយោគវិស័យឯកជនក្នុងការអភិវឌ្ឍន៍ធារាសាស្ត្រ* |
| ការឯកភាពនៅក្នុងវិស័យក្នុងការអនុវត្តន៍យុទ្ធសាស្ត្រនិងគោលនយោ | - *% នៃទីភ្នាក់ងារផ្តល់ជំនួយដែលចុះហត្ថលេខាលើ MOU ជាមួយក្រសួងធនធានទឹក និងឧតុនិយម អំពីយុទ្ធសាស្ត្រនិងគោលនយោបាយ PIM ( គោលនយោបាយ ១.៤& ២.៥)*<br>- *% នៃជំហាន PIM ដែលតាមគំរោងនិមួយៗ* |
| តម្លៃប្រព័ន្ធធារាសាស្ត្រ (គោលនយោបាយ ១.៤) | - *ទំនោរនៃការចំណាយប្រចាំឆ្នាំរបស់រដ្ឋាភិបាលសំរាប់ប្រព័ន្ធធារាសាស្ត្រ O&M/ ហិតា*<br>- *ទំនោរនៃការចំណាយប្រចាំឆ្នាំរបស់រដ្ឋាភិបាលរបស់ ស.ក.ប.ទ សំរាប់ O&M/ ហិតា*<br>- *ទំនោរនៃការចំណាយប្រចាំឆ្នាំរបស់រដ្ឋាភិបាលបូក& ការចំណាយរបស់ ស.ក.ប.ទ សំរាប់ O&M/ ហិតា* |
| ការបន្ថែមតម្លៃ (ការបូកផ្សំ) | - *ការអនុម័តការអនុវត្តន៍កសិកម្មបែបថ្មីដែលបានបង្ក* |

| | |
|---|---|
| ពីអន្តរាគមន៍រួមលើការអភិវឌ្ឍន៍ ធារាសាស្ត្រ&កសិកម្មចំពោះ យុទ្ធសាស្ត្រ PIM | *លក្ខណៈងាយស្រួលដោយ PIM* |
| (គោលនយោបាយ ២.៥) | |
| កសិករយល់ដឹងអំពី PIMD | *- ឆ្លើយតបនិងសំណូរសំខាន់ៗក្នុងក្រុមសម្ភាសន៍* |
| កសិករទទួលយក PIMD | *- ស.ក.ប.ទ អនុលោមតាមគោលការណ៏គន្លឹះរបស់ PIM ដោយមានប្រជាធិបតេយ្យតម្លាភាព និងគណនីភាព* |
| *ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងពាក់ព័ន្ធ* មន្ត្រីរដ្ឋាបាលមូលដ្ឋានយល់ដឹង PIM | *- ឆ្លើយតបនិងសំណូរសំខាន់ៗក្នុងក្រុមសម្ភាសន៍(ក្នុងវគ្គបណ្តុះបណ្តាល)* |
| *ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងពាក់ព័ន្ធ និង* មន្ត្រីរដ្ឋបាលមូលដ្ឋានគាំទ្រ PIMD | *- មន្ត្រីទាំងអស់អនុលោមតាមយុទ្ធសាស្ត្រនិងគោលនយោបាយ PIMD* |

## ៦.៥.សន្ទស្សន៍អំពីផលប៉ះពាល់

| **<u>គោលដៅផលប៉ះពាល់របស់គោលនយោបាយ</u>** | **- <u>សន្ទស្សនជាយថាហេតុ</u>** |
|---|---|
| " សន្តិសុខស្បៀង " (គោលនយោបាយ ១.១) | *- ទិន្នផលស្រូវ (kg/ ហិតា) (គោលនយោបាយ ១.១)* |
| | *- ប្រពលភាពដំណាំ (១៩= ១០០) (គោលនយោបាយ ២.៧)* |
| "ការធ្វើពាណិជ្ជកម្មលើកសិកម្ម " (គោលនយោបាយ ២.៧) ប្រពន្ធ័ធារាសាស្ត្រមាននិរន្តរភាព និងបរិស្ថានល្អ (គោលនយោបាយ ១.៤) | *-% ការស្រោចស្រពក្នុងរដូវប្រាំងលើដីដែលមិនដាំស្រូវ*<br>*- ចំនួនប្រភេទដំណាំដែលដាំក្នុងសំណាង*<br>*- អត្រាដីល្បាប់ក្នុងប្រឡាយ*<br>*- ជំរៅរហូតដល់ស្រទាប់ទឹកក្រោមដីក្នុងរដូវប្រាំង*<br>*- ជំរៅដីមានជីរជាតិខ្ពស់*<br>*- ថ្នាំសម្លាប់សត្វល្អិតដែលនៅសេសសល់ក្នុងទឹកដែលបង្ហូរ*<br>*-% តំបន់អាចស្រោចស្រពបាត់បង់ក្នុងផលិតដោយសារទឹកជោគជន់ពេកឬដោយសារឱនភាពនៃធនធានឯទៀត*<br>*- ចំណែកនៃតំបន់បានស្រោចស្រពទៅដល់តំបន់អាចស្រោច* |

| | |
|---|---|
| | *ស្រពដើមដំបូង* |
| ការកាត់បន្ថយភាពក្រីក្រ | *- មធ្យមភាគនៃប្រាក់ចំណូលពីកសិដ្ឋានសុទ្ធ($/ ឆ្នាំ)* |
| (មិនមានចែងក្នុងគោលនយោបាយ) | *- អត្រាថ្លៃឈ្នួលកសិកម្ម($/ ថ្ងៃ)* |
| | *- % នៃប្រជាជនរស់ក្រោមបន្ទាត់ក្រីក្រ* |
| ផលិតភាពសេដ្ឋកិច្ចនៃប្រពន្ធ័ | *- តម្លៃសរុបនៃផលិតផល/ ហិកតា/ ឆ្នាំ* |
| ធារាសាស្ត្រ | *- អត្រាដោះស្រាយការងារក្នុងប្រពន្ធ័ធារាសាស្ត្រ* |
| (មិនមានចែងក្នុងគោលនយោបាយ) | *(មនុស្សថ្ងៃ/ ហិកតា/ រដូវ)* |
| | *- ទំនោរក្នុងអត្រាថ្ងៃឈ្នួលកសិកម្ម* |

## ៧.ជំហានទី ៣ : ការប្រមូលនិងគ្រប់គ្រងទិន្នន័យ

### *៧.១.ផែនការប្រមូលទិន្នន័យ*

កិច្ចការទីមួយគឺត្រូវរកអង្គភាពឬកិរិតដែលសន្ទស្សន៍ត្រូវវាស់ស្ទង់បន្ទាប់មកត្រូវបញ្ជាក់អំពីប្រភពទិន្នន័យ ។ ទំរង់បែបប្រមូលទិន្នន័យគឺជាឧបករណ៍ផែនការយ៉ាងមាន ប្រយោជន៍សំរាប់ធ្វើការតាមរយៈជំហានទាំងពីរនេះ ។ ឧទាហរណ៍ នៃទំរង់បែបបទប្រមូលទិន្នន័យបានផលនៅក្នុងតារាងទីបីដើម្បីជាការណែនាំ ។ ទំរង់នេះគ្រាន់តែជាឧទាហរណ៍ហើយគួរតែពិនិត្យនិងកែតំរូវតាមត្រូវការ ។ ប្រភពទិន្នន័យ និងវិធីសាស្ត្រប្រមូលទិន្នន័យគួរស្នើឡើងដោយអ្នកចូលរួមក្នុងសិក្ខាសាលាជាតិអំពី M&E សំរាប់ PIMD ហើយត្រូវសំរេចដោយ លេខាធិការដ្ឋានជាតិ ។

### *៧.២.ផែនការគ្រប់គ្រង និងបញ្ចូលទិន្នន័យ*

គួរផ្ទេរទិន្នន័យពីក្រដាសសំណួរឬទំរង់បែបបទដើមដោយបញ្ចូលក្នុង disks កំព្យូទ័រភ្លាមក្រោយពីប្រមូលទិន្នន័យរួច ។ ការបញ្ចូលនេះអាចធ្វើឱ្យងាយស្រួលក្នុងការរកកំហុសនិងកែតំរូវខណៈដែលអ្នកប្រមូលទិន្នន័យកំពុងស្ថិតនៅ ជិតសំណង់នៅឡើយឬខណៈដែលអ្នកប្រមូលទិន្នន័យនៅចងចាំខ្លឹមសារនៃការសម្ភាសន៍ ឬការត្រួតពិនិត្យនៅឡើយ ។ បើអាចធ្វើបានបុគ្គលិកគ្រប់គ្រងទិន្នន័យម្នាក់ដែលនៅក្នុងក្រុមទ្រទ្រង់ ស.ក.ប.ទ គួរបញ្ចូលទិន្នន័យ M&E ភ្លាមក្រោយពេលប្រមូលទិន្នន័យរួចហើយ ។ ប្រសិនបើនៅទីតាំង នោះមិនមាន Laptop computer ទេ បន្ទាប់មកត្រូវតែមកកាន់ការិយាល័យស្រុកឬខេត្តដែលមាន Desktop computer ។ លេខាធិការដ្ឋានជាតិគួរជ្រើសរើសអ្នកជំនាញខាងគ្រប់គ្រងទិន្នន័យម្នាក់ឱ្យជួយតម្លើងឧបករណ៍សំរាប់បញ្ចូលទិន្នន័យ និងតម្លើងនិមិត្តសញ្ញាដល់សន្ទស្សន៍និងតម្លៃជាយថាហេតុរបស់វា Micrsoft Excel និងបំរើបានយ៉ាងគ្រប់គ្រាន់ជា Software សំរាប់ការបញ្ចូលទិន្នន័យ ការពិនិត្យបង្ហាញស្ថិតិងាយយល់និង charts ។ វាមានប្រយោជន៍ជាទីបំផុត ហើយបានទទួលស្គាល់ថាងាយប្រើប្រាស់ ក្រោយមក នៅពេលដែលសំណង់ធារាសាស្ត្រច្រើនទៀតត្រូវបានបញ្ចូលក្នុង សកម្មភាព PIMD ហើយ មូលដ្ឋានទិន្នន័យត្រូវពង្រីក ហើយកាន់តែមានភាពស្មុគ្រស្មាញនោះវានឹងអាចឱ្យភ្ជាប់ទៅកម្មវិធីទំនាក់ទំនងមូលដ្ឋានទិន្នន័យមួយដូចជា Microsoft Access សំរាប់ការបញ្ចូលទិន្នន័យក្នុងកម្មវិធី

Spreadsheett ដូចជា Excel ឯកសារទិន្នន័យទាំងអស់គួររៀបជារចនាសម្ព័ន្ធជាមួយសន្ទស្សន៍និមួយៗ (ឬអាចផ្លាស់ប្តូរ) ដែលឱ្យខ្ទង់តែមួយចំណែកឯជួរបន្ទាត់ត្រូវបានប្រើសំរាប់ករណីផ្សេងៗ (កសិករ រចនាសម្ព័ន្ធ ឬទីតាំង)។ អ្នកជំនាញខាងគ្រប់គ្រងទិន្នន័យគួរប្រាកដក្នុងចិត្តថាអ្នកគ្រប់គ្រងទិន្នន័យថ្នាក់ខេត្តសំរាប់ប្រពន្ធ័ M&E (ដែលជារបស់ក្រុមទ្រទ្រង់ ស.ក.ប.ទ )គួរបញ្ជាក់ភាពខុសគ្នាឱ្យច្បាស់រវាងតម្លៃដែលខកខាន (ដែលមិនបាន ទទួលទិន្នន័យ) ទល់និងតម្លៃសូន្យ (ដូចជាមិនបានបង់ថ្លៃឈ្នួល)។ អ្នកជំនាញខាង គ្រប់គ្រងទិន្នន័យគួរតាងសញ្ញា ឬលេខសំរាប់ " តំលៃដែលខកខាន " ទល់និង 0 សំរាប់តម្លៃសូន្យ។

ការបញ្ចូលទិន្នន័យងាយខុសណាស់ហើយកំហុសជាច្រើនអាចធ្វើឱ្យទិន្នន័យគ្មានប្រយោជន៍។ ដូច្នេះជាសំខាន់អ្នក ជំនាញខាងគ្រប់គ្រងទិន្នន័យបង្កើតការរៀបចំពិនិត្យទិន្នន័យចំណែកឯអ្នកទីពីរត្រូវពិនិត្យការជ្រើសគំរូដែលបញ្ចូលក្នុង Spreadsheet ដោយប្រៀបធៀបជាមួយទិន្នន័យដើម។ លំដាប់នៃតំលៃដែលអាចទទួលយកបានមួយគួរបញ្ជាក់ក្នុង Excel ដើម្បីឱ្យកម្មវិធីអាចចាប់បាន និងផ្តល់សញ្ញាដល់អ្នកបញ្ចូលទិន្នន័យអំពីកំហុសក្នុងការបញ្ចូលទិន្នន័យនោះ។ បុគ្គលិកគ្រប់គ្រងទិន្នន័យនៅថ្នាក់ខេត្តគួរប្រមូលផ្តុំទិន្នន័យពីកសិករ និងកំរិតឃុំដល់កំរិតសំណង់និងកំរិតខេត្ត។ អ្នកជំនាញខាងគ្រប់គ្រងទិន្នន័យអំពីលេខាធិការដ្ឋានជាតិគួរបង្កើតមូលដ្ឋានទិន្នន័យនៅថ្នាក់ជាតិ ប្រមូលផ្តុំទិន្នន័យទាំងអស់ពីថ្នាក់ខេត្តដល់ថ្នាក់ជាតិ។

### *៧.៣.ទំរង់បែបបទ Matrix ការទទួលខុសត្រូវ : ផែនការសំរាប់ នរណាធ្វើអ្វី*

ទំរង់បែបបទ Matrix ការទទួលខុសត្រូវជាឧបករណ៍ផែនការដើម្បីបង្ហាញអ្នកពាក់ពន្ធ័ផ្សេងៗដែលពាក់ពន្ធ័ក្នុងកម្មវិធី M&E អំពីតួនាទី និងការទទួលខុសត្រូវ។ ទំរង់បែបបទប្រើប្រាស់ដើម្បីសំរបសំរួលការពិភាក្សាក្នុងសិក្ខាសាលាឬក្នុងកិច្ចប្រជុំធ្វើផែនការក្រៅផ្លូវការ ។នៅពេលដែលបំពេញរួចហើយ គួរចែកចាយទំរង់ បែបបទនេះឱ្យដល់អ្នកពាក់ពន្ធ័ទាំងអស់ ដើម្បីឱ្យពួកគេយល់ច្បាស់អំពីតួនាទីរបស់ពួកគេនៅក្នុងដំ ណើរការនេះ។ តារាងទី ៤ ខាងក្រោមបង្ហាញឧទាហរណ៍មួយអំពីសណ្ឋានរបស់ទំរង់បែបបទ Matrix ការទទួលខុសត្រូវ។ នៅក្នុង cells និមួយៗមានអក្សរ "X" (មានន័យថាគ្មានតួនាទី ) ឬការពន្យល់ខ្លីៗ អំពីកិច្ចការដែលត្រូវអនុវត្តដោយអ្នកពាក់ពន្ធ័។

## ៨.ជំហានទី ៤: របាយការណ៍ និងការប្រើប្រាស់លទ្ធផល M&E

### *៨.១.រៀបចំកិច្ចប្រជុំពិនិត្យ PIMD ឡើងវិញ និងការបង្ហាញលទ្ធផល*

ខាងក្រោមនេះគឺជាប្រភេទនៃកិច្ចប្រជុំដែលមានសារៈសំខាន់ជាទីបំផុតសំរាប់បង្ហាញនិងពីភាក្សាលទ្ធផល M&E :

១-កិច្ចប្រជុំប្រចាំខែដើម្បីពិនិត្យទុនឡើងវិញ-នៅក្នុងកិច្ចប្រជុំនេះមានការបង្ហាញនិងពិភាក្សាអំពីការចំណាយ របស់ PIMD ការចាត់តាំងបុគ្គលិក(សំរាប់ PIMD)។ សំណើសុំឱ្យកែតំរូវទំរង់ចំណាយនិងនិតិវិធីត្រូវបានចេញផ្សាយនៅពេលប្រជុំនេះ។

២-កិច្ចប្រជុំប្រចាំត្រីមាសដើម្បីពិនិត្យការអនុវត្តន៍ឡើងវិញ-លទ្ធផលនៃការត្រួតពិនិត្យការអនុវត្តន៍ត្រូវបានបង្ហាញនិងពិភាក្សា ។ សំណើសុំឱ្យមានការកែតំរូវនិតិវិធីត្រូវបានចេញផ្សាយ ។

៣- កិច្ចប្រជុំប្រចាំឆ្នាំដើម្បីពិនិត្យលទ្ធផលឡើងវិញ-លទ្ធផលពីការតាមដានលទ្ធផលរបស់ PIMD ត្រូវបានបង្ហាញនិងពិភាក្សា ។ សំណើសុំផ្លាស់ប្តូរយុទ្ធសាស្ត្រត្រូវបានចេញផ្សាយ ។

៤- កិច្ចប្រជុំពិនិត្យឡើងវិញការវាយតំលៃផលប៉ះពាល់ (ក្រោយពេល៥ឆ្នាំ)-លទ្ធផលពីការស្ទាបស្ទង់មូលដ្ឋានដើមការតាមដានលទ្ធផលប្រចាំឆ្នាំនិងទិន្នន័យពិសេសដែលបានប្រមូលសំរាប់ការវាយតំលៃផលប៉ះពាល់ត្រូវបានបង្ហាញ ។ អាចធ្វើការប្រៀបធៀបមុនពេលនិងក្រោយពេលPIMDឬដោយមាន និងដោយ គ្មាន PIMD ។ តារាងនិង chartsសំរាប់ការបង្ហាញគួររៀបចំតាមវិធីមួយដែលអាចឱ្យការប្រៀបធៀប ទាំងនេះមានភាពជាក់ច្បាស់ ។ ជាការបន្ថែមលើកិច្ចប្រជុំទាំងនេះ ជាចាំបាច់ត្រូវមានកិច្ចប្រជុំឯទៀតដែលសមស្របសំរាប់អ្នកពាក់ពន្ធ័ពិសេសៗ ។ សំរាប់មន្ត្រីនិងអ្នកនយោបាយជាន់ខ្ពស់ ការបង្ហាញផ្ទាល់ខ្លួនខ្លីៗដោយមាន charts តែ ៣ ឬ ៤ និងអ្នកធ្វើផែនការថ្នាក់កណ្តាលសិក្ខាសាលាពិភាក្សាអាចជាមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការពិភាក្សាលទ្ធផល ។ ប៉ុន្តែគ្រប់ករណីទាំងអស់ ការបង្ហាញដោយត្រង់ៗនិងងាយៗមានប្រសិទ្ធិភាពជាងការបង្ហាញដោយលំអិត ។

## *៨.២.ការប្រើប្រាស់M&E ដើម្បីគាំទ្រការធ្វើសេចក្តីសំរេចចិត្ត*

ប្រភេទនៃកិច្ចប្រជុំពិនិត្យឡើងវិញរបស់ PIMD ទាំង ៤ យ៉ាង (ទុន ការអនុវត្តន៍ លទ្ធផល និងផលប៉ះពាល់) ផ្តល់មូលដ្ឋានសំរាប់ធានាថាលទ្ធផល M&E ត្រូវបានរៀបចំនិងបង្ហាញ ដើម្បីឱ្យវាផ្តល់ពត៌មានពាក់ពន្ធ័នៅពេលដែលត្រូវការធ្វើសេចក្តីសំរេចចិត្តផែនការនិងកម្មវិធីន PIMD ។ លេខាធិការដ្ឋានជាតិគួរជួបក្រុមទ្រទ្រង់ ស.ក.ប.ទ ថ្នាក់ខេត្ត និង ស.ក.ប.ទ យ៉ាងទៀងទាត់ដើម្បីពួកគេបានដឹងអំពីបញ្ហាដែលកើតឡើង ។ យ៉ាងហោចណាស់រយៈពេល ៣ សប្តាហ៍មុនពេលកិច្ចប្រជុំពិនិត្យ M&E ឡើងវិញ លេខាធិការដ្ឋានជាតិគួរផ្តល់បញ្ជីបញ្ហាសំខាន់ៗដែលគួរឱ្យទៅអនុគណៈកម្មាធិការ M&E ដើម្បីអនុគណៈកម្មាធិការនេះអាចរៀបចំការបង្ហាញរបស់ខ្លួនក្នុងកិច្ចប្រជុំបន្ទាប់ដោយអនុលោមតាមចំនុចនៃការធ្វើសេចក្តីសំរេចចិត្តសំខាន់ៗដែលនឹងមានចែងលើរបៀបវារៈ ។

នាយកប្រតិបត្តិនៃលេខាធិការដ្ឋានជាតិគួរជាប្រធានដឹកនាំកិច្ចប្រជុំពិនិត្យ PIMD ឡើងវិញទាំងអស់ ហើយ សង្កត់ធ្ងន់លើសារៈសំខាន់ៗនៃការប្រៀបធៀបលទ្ធផល M&E ជាមួយគោលបំណងយុទ្ធសាស្ត្រ និងគោលនយោបាយជាផ្លូវការ ។ នាយកប្រតិបត្តិក៏គួរសង្កត់ធ្ងន់លើការបញ្ចប់ប្រធានបទនិមួយៗដោយមានកិច្ចព្រមព្រៀងអំពីសកម្មភាពច្បាស់លាស់សំរាប់ M&E ឬសំរាប់កែលំអរដំណើរការ PIMD ។

## ៩.ឧទាហរណ៍នៃទំរង់បែបបទផែនការសំរាប់ប្រពន្ធ័ M&E

នៅក្នុងឧបសម្ពន្ធ័ខាងក្រោមគឺជាឧទាហរណ៍នៃទំរង់បែបបទដែលអាចប្រើប្រាស់សំរាប់រៀបផែនការ និងតំរូវការធ្វើសេចក្តីសំរេចចិត្តរបស់ក្រុមទ្រទ្រង់ ស.ក.ប.ទ និងលេខាធិការដ្ឋានជាតិ ។

## ១០.ក្រុមលំហាត់ដែលបានស្នើឡើងសំរាប់មេរៀនទី ៦ វគ្គទី ១

### <u>លំហាត់ទី ១ : របាយការណ៍</u>

គ្រូឧទ្ទេសនាមចាត់តាំងសិក្ខាកាមពីរនាក់ឱ្យធ្វើជាអ្នករាយការណ៍សំរាប់វគ្គទីមួយនៃមេរៀនទី ៦ ។ ពួកគេនឹងសរសេររបាយការណ៍ខ្លីអំពីចំណុចសំខាន់ៗនៅក្នុងបឋកថានិងលំហាត់ដោយមានការចូលរួម ។ ពួកគេគួររៀបចំរបាយការណ៍នេះក្នុងអំឡុងពេលមួយថ្ងៃ បន្ទាប់ពីវគ្គទី ១ បានបញ្ចប់សព្វគ្រប់ ។

### <u>*លំហាត់ទី ២ : ការបញ្ចេញយោបល់អំពីសន្ទស្សន៍*</u>

ជំហានទី **១** : សិក្ខាកាមជួបគ្នាក្នុងក្រុមតូចៗពិភាក្សាគ្នាដើម្បីរក :

**១**)- ទិន្នន័យសង្គម-សេដ្ឋកិច្ចទូទៅ បច្ចេកទេសជារូបវន្តនិងកសិកម្ម

**២**)- សន្ទស្សន៍សំរាប់កម្មវិធីអនុវត្ត

៣)- គោលបំណងនិងសន្ទស្សន៍សំរាប់លទ្ធផលដំបូង

៤)- គោលបំណងនិងសន្ទស្សន៍សំរាប់ផលប៉ះពាល់ចុងក្រោយ

ក្រុមនិមួយៗគួរមានអ្នកជំនាញការចំរុះ (វិស្វកម្ម កសិកម្ម សេដ្ឋកិច្ច-សង្គម ។ល ។)

ជំហានទី ២ : អ្នកតំណាងក្រុមពិភាក្សានិមួយៗបង្ហាញលទ្ធផលតាមក្រុមដល់សិក្ខាកាមទាំងអស់ក្នុងកិច្ចប្រជុំពេញអង្គ ។ សិក្ខាកាមបញ្ចេញមតិ និងសំណើលើការបង្ហាញនិមួយៗ ។

ជំហានទី ៣ : អ្នកបង្ហាញនិមួយៗរៀបចំសរសេរសង្ខេបនូវអនុសាសន៍របស់ក្រុមអំពីសន្ទស្សន៍ហើយកែតំរូវបន្ទាប់ពីពិភាក្សាពេញអង្គ ។

### <u>*លំហាត់ទី ៣ : ការពិនិត្យឡើងវិញ*</u>

ជំហានទី ១ : នៅចុងបញ្ចប់មេរៀនទី ៦ វគ្គទី ១ គ្រូឧទ្ទេសនាមស្នើឱ្យសិក្ខាកាមរៀបរាប់ពីអ្វីដែលពួកគេយល់ថាជាចំណុចសំខាន់បំផុតក្នុងមេរៀនទី ៦ វគ្គទី ១ ។

ជំហានទី ២ : អ្នករាយការណ៍អានរបាយការណ៍សង្ខេប វគ្គទី ១ ។

ជំហានទី ៣ : គ្រូឧទ្ទេសនាមសួរសិក្ខាកាមប្រសិនបើពួកគេចង់បន្ថែមឬកែតំរូវក្នុងរបាយការណ៍នោះ ។

ជំហានទី ៤ : អ្នករាយការណ៍កត់ត្រាសំណើ ហើយកែតំរូវរបាយការណ៍ វគ្គទី ១ តាមត្រូវការ ។

## ១១- **សង្ខេបមេរៀន**

